សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights





# ហានិភ័យ នៃសំឡេងរិះគន់៖
## ការរំលោភបំពានទៅលើអ្នកការពារសិទ្ធិមនុស្ស

របាយការណ៍សង្ខេប
ចេញខែកក្កដាឆ្នាំ២០១៧

# ហានិភ័យ នៃសំឡេងរិះគន់៖

## ការរំលោភបំពានទៅលើអ្នកការពារសិទ្ធិមនុស្ស

របាយការណ៍សង្ខេបចេញខែកក្កដា ឆ្នាំ២០១៧


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការឆ្លើយតបទៅនឹងការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា




ហានិភ័យនៃសំឡេងរិះគន់៖ ការរំលោភបំពានទៅលើអ្នកការពារសិទ្ធិមនុស្ស ទំព័រ១

ការបង្ក្រាបទៅលើសេរីភាពជាមូលដ្ឋាននានា ទំព័រ២

អំពើហិង្សាដែលគាំទ្រដោយអាជ្ញាធរ ទំព័រ៦

ការរំលោភបំពានដោយប្រព័ន្ធតុលាការ៖ ការចោទប្រកាន់ព្រហ្មទណ្ឌលើអ្នករិះគន់ ទំព័រ៩

ការតវ៉ា និងការតស៊ូដោយអហិង្សា៖ ក្តីសង្ឃឹមសម្រាប់ អនាគត ទំព័រ១៧

អនុសាសន៍ ទំព័រ១៨

ឧបសម្ព័ន្ធ៖ ការរំលោភបំពានទៅលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (២០១៥-២០១៧) ទំព័រI


រូបគំរបមុខ៖ ខាងមុខសាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៦

# ហានិភ័យនៃសំឡេងរិះគន់ ៖ ការរំលោភបំពាននៅលើអ្នកការពារសិទ្ធិមនុស្ស

នៅក្នុងខែមិថុនា ឆ្នាំ២០១៧ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ហើយការបោះឆ្នោតថ្នាក់ជាតិនឹងត្រូវប្រព្រឹត្តទៅនៅឆ្នាំក្រោយ។ លទ្ធផលដែលនឹងកើតចេញនៅអំឡុងពេលពីរឆ្នាំខាងមុខអាចនឹងមានឥទ្ធិពលបន្តរយៈពេលរាប់សិបឆ្នាំទៅមុខទៀត។ ដូចដែលបានកើតឡើងនៅគ្រប់ការបោះឆ្នោតរាប់តាំងពីឆ្នាំ១៩៩៣មករាជរដ្ឋាភិបាលបច្ចុប្បន្នមានជំនឿថានឹងបន្តកាន់អំណាចទៅមុខទៀត៖ នៅខណៈដែលការបោះឆ្នោតខិតជិតមកដល់ គណបក្សកាន់អំណាច (ដែលបានកាន់អំណាចនៅកម្ពុជាអស់រយៈពេលជាង ៣០ឆ្នាំ) កាន់តែបង្កើនការបន្ថយមតិរិះគន់ និងសំឡេងបុគ្គលណាដែលមិនយល់ស្របនឹងការអត្ថាធិប្បាយរបស់អាជ្ញាធរ។

នៅខណៈដែលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាហាក់ដូចជាមិនដើរទៅមុខ ការនិយាយរិះគន់ទៅលើការរំលោភបំពានរបស់អាជ្ញាធរ គឺកាន់តែមានសារសំខាន់ខ្លាំងឡើង។ នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ អ្នកការពារសិទ្ធិមនុស្ស បុគ្គលឯករាជ្យ និងបុគ្គលសំខាន់ៗមួយចំនួនទៀត បានក្លាយជាជនរងគ្រោះក្នុងចំណោមជនរងគ្រោះដទៃទៀត នៅក្នុងស្ថានភាពនយោបាយដ៏ផុយស្រួយនៅកម្ពុជា។ អ្នកការពារសិទ្ធិមនុស្សមួយចំនួន ប្រឈមមុខនឹងបទចោទប្រកាន់ដែលគ្មានមូលដ្ឋានត្រឹមត្រូវ ជាប់ឃុំក្នុងពន្ធនាគារ ឬប្រឈមមុខនឹងការរំលោភបំពាន ការបំភិត-បំភ័យ និងការតាមដានពីជនមិនស្គាល់អត្តសញ្ញាណ។ ខណៈក្រុមសង្គមស៊ីវិលបានបង្ហាញពីសេចក្តីក្លាហាននិងការតស៊ូ ឥទ្ធិពលអវិជ្ជមាននៃហានិភ័យជាច្រើននៅតែមានសម្រាប់អ្នកទាំងនោះ និងទៅលើគ្រប់ទម្រង់នៃសំឡេងរិះគន់នៅទូទាំងប្រទេស ដែលអាចជាផលប៉ះពាល់ដល់ការបោះឆ្នោតខាងមុខ។

ទោះបីជាអាជ្ញាធរកាន់តែបង្ហាញឆន្ទៈក្នុងការដាក់ទណ្ឌកម្ម លើការអនុវត្តសិទ្ធិ និងសេរីភាពដោយអហិង្សា ដែលអាជ្ញាធរសន្និដ្ឋានថាជាការគំរាមកំហែងដល់ស្ថាប័នគ្រប់គ្រងអំណាចក៏ដោយ ក៏អ្នកការពារសិទ្ធិមនុស្សនៅតែមិននៅស្ងៀមក្នុងការទាមទាររកយុត្តិធម៌ឡើយ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ អ្នកការពារសិទ្ធិមនុស្សមួយចំនួនបានបន្តដើរតាមដងផ្លូវ ទប់ទល់នឹងការគំរាមកំហែង និងការបំភិតបំភ័យដែលអាចប្រឈមមុខនឹងការជាប់ពន្ធ-នាគារ ដើម្បីទាមទារសិទ្ធិរបស់អ្នកទាំងនោះ និងក្រោកឈរតវ៉ាដើម្បីសហគមន៍និងសហជីពរបស់ពួកគេ។

# ការបង្ក្រាបនៅលើសេរីភាពជាមូលដ្ឋាននានា

នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ការប្រមូលផ្ដុំដោយអហិង្សាតែងតែត្រូវបានបំបែក ហើយអ្នកតវ៉ាមួយចំនួនត្រូវបានឃាត់និងចាប់ខ្លួន។ ម្ដងហើយម្ដងទៀត ការបន្តអនុវត្តសិទ្ធិសេរីភាពក្នុងការប្រមូលផ្ដុំ និងបញ្ចេញមតិដោយអហិង្សារបស់អ្នកការពារសិទ្ធិមនុស្ស ត្រូវបានរារាំងដោយការប្រើប្រាស់កងកម្លាំងច្រើនលើសលុបនិងមិនត្រឹមត្រូវ ហើយការបញ្ចេញមតិខ្លះតាមប្រព័ន្ធអ៊ិនធើណេត ត្រូវបានអាជ្ញាធរចាប់មកផ្ដន្ទាទោស។ នៅខណៈដែលការបោះឆ្នោតកាន់តែខិតជិតមកដល់ ការគំរាមកំហែងកាន់តែកើនឡើងតាមរយៈវោហាសាស្ត្រពីរាជរដ្ឋាភិបាល និងកងកម្លាំងប្រដាប់អាវុធ ដែលប្រដូចការប្រមូលផ្ដុំ និងការបញ្ចេញមតិដោយអហិង្សាទៅនឹង"បដិវត្តន៍ពណ៌"។

ការតវ៉ាមួយចំនួនដែលជំទាស់ទៅនឹងគោលនយោបាយខ្លះ របស់អាជ្ញាធរ ត្រូវបានបង្ក្រាបនិងបំភិតបំភ័យ (ពេលខ្លះរួមទាំងការបង្ក្រាបដោយហិង្សាក៏មានដែរ) ហើយនិងត្រូវបានរឹតត្បិតកាន់តែខ្លាំងឡើងៗ។ ការដាក់ពង្រាយកងសន្តិសុខ នគរបាលបង្ក្រាបបាតុកម្ម កងរាជអាវុធហត្ថ និងទាហាន ដើម្បីរំខានដល់ការប្រមូលផ្ដុំដោយអហិង្សាបានកើតឡើងស្ទើរតែរាល់លើក។ អាជ្ញាធរបន្តប្រើប្រាស់ច្បាប់ដោយមិនត្រឹមត្រូវ ដើម្បីបដិសេធការប្រមូលផ្ដុំ ការតវ៉ា និងបាតុកម្មផ្សេងៗ។

ឧទាហរណ៍ កាលពីខែធ្នូ ឆ្នាំ២០១៦ អ្នកការពារសិទ្ធិមនុស្សនិងពលរដ្ឋជាច្រើននាក់ ដែលបានប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ត្រូវបានរារាំងដោយមិនអនុញ្ញាតឲ្យធ្វើការដង្ហែក្បួន និងប្រមូលផ្ដុំគ្នានៅតំបន់ជាក់លាក់មួយចំនួននៅក្នុងរាជធានីភ្នំពេញនោះទេ ហើយត្រូវបានបង្ខំឲ្យប្រារព្ធនៅក្នុងទីលានប្រជាធិបតេយ្យ ដោយការដាក់ពង្រាយនគរបាលបង្ក្រាបបាតុកម្មយ៉ាងច្រើនដែលប្រដាប់ដោយដំបង ខែល និងឧបករណ៍បង្ហូរទឹកភ្នែក។ ទោះបីជានៅក្នុងទីលានប្រជាធិបតេយ្យក៏ដោយ ក៏ការប្រមូលផ្ដុំគ្នាត្រូវបានឡោមព័ទ្ធដោយកងនគរបាលរាប់រយនាក់រហូតដល់កម្មវិធីចប់សព្វគ្រប់។[១] ផ្នែកមួយដែលជាការកើនឡើងនៃការរឹតត្បិតលំហនៃសេរីភាព ទីលានប្រជាធិបតេយ្យ (ជាទីលានមួយនៅកណ្ដាលរាជធានីភ្នំពេញ ដែលត្រូវបានបង្កើតឡើងជាទីតាំងសម្រាប់ការតវ៉ាផ្សេងៗ ដែលការតវ៉ាទាំងនោះកាន់តែរីកធំឡើងៗ រាប់ចាប់តាំងពីមានការតវ៉ាធំៗរបស់គណបក្សជំទាស់នៅក្រោយការបោះឆ្នោតឆ្នាំ២០១៣) ត្រូវបានអាជ្ញាធរផ្លាស់ប្ដូរទៅកាន់ទីតាំងថ្មីនៅជាយរាជធានីភ្នំពេញ នៅប៉ុន្មានខែចុងក្រោយមុនការបោះឆ្នោតមកដល់ បន្ទាប់ពីសម្ដេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ការទុកទីលានប្រជាធិបតេយ្យនៅទីតាំងចាស់នោះ បានបង្កនូវ"ភាពអនាធិបតេយ្យ"។[២]

---

[១] LICADHO, Celebrating International Human Rights Day Across Cambodia (http://www.licadho-cambodia.org/flashnews.php?perm=200)
[២] Cambodia Daily, Freedom Park May Move North of City, Hun Sen Says (https://www.cambodiadaily.com/subscribe/?level=&status=&id=0&archive=1)



ការប្រមូលផ្ដុំប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ នៅទីលានប្រជាធិបតេយ្យ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦

វេទិកាថ្នាក់សហគមន៍មួយចំនួនក៏មិនត្រូវបានលើកលែងផងដែរ៖ នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ សិក្ខាសាលា និងសកម្មភាពជាច្រើន ស្តីពីដីធ្លី និងសិទ្ធិបរិស្ថាន ត្រូវបានបិទដោយអាជ្ញាធរនៅទូទាំងប្រទេស។ កាលពីខែមិនា ឆ្នាំ២០១៦ ក្រុមនគរបាលចំរុះជាមួយនឹងកងរាជ-អាវុធហត្ថ ត្រូវបានដាក់ពង្រាយ ដើម្បីរារាំងក្រុមជនជាតិដើមភាគតិចពីការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់សហគមន៍នៅក្នុងខេត្តរតនគិរី។ ហើយនៅខែវិច្ឆិកា ឆ្នាំ ២០១៦ នគរបាលបានបិទការប្រជុំមួយដែលរៀបចំឡើងដោយអង្គការមាតាធម្មជាតិដើម្បីពិភាក្សាអំពីផលប៉ះពាល់នៃការបូមខ្សាច់នៅក្នុងខេត្តកោះកុង។ ការឆ្លើយតបបែបនេះទៅលើការពិភាក្សាអំពីផលប៉ះពាល់នៃការអភិវឌ្ឍគឺជាការរំលោភបំពានទៅលើសិទ្ធិ នៃក្រុមសង្គមស៊ីវិលទាំងមូល ហើយផ្ញើជាសារអវិជ្ជមានដល់អ្នកការពារសិទ្ធិមនុស្សផ្សេងទៀតដែលរៀបចំ ឬដឹកនាំកម្មវិធីបែបនេះ។

នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ អង្គការលីកាដូ បានស្រាវជ្រាវនិងតាមដានករណីជាង ១០០ ស្តីពីការរារាំងសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំ ឬសេរីភាពក្នុងការបញ្ចេញមតិ ដោយបង្ហាញថាមានការកើនឡើងជិតបីដងនៅក្នុងករណីនេះ ចាប់ពីឆ្នាំ២០១៥ ដល់ ២០១៦។ នៅក្នុងអំឡុងពេលបីខែដើមឆ្នាំ ២០១៧ មានបីករណី។ ការបង្ក្រាបដែលបន្តកើតមាន និងក្រោមរូបភាពជាច្រើនយ៉ាងទៅលើសេរីភាពនៃការប្រមូលផ្តុំដោយអហិង្សា និង ការបញ្ចេញមតិបែបនេះ បានលុបបំបាត់ទម្រង់នៃកិច្ច ពិភាក្សា និង គំនិតរិះគន់ដែលសំខាន់ៗនិងស្របច្បាប់មួយចំនួនដែលនេះជាហានិភ័យនៅក្នុងបរិបទមុនការបោះឆ្នោត មកដល់។

## ការរំលោភបំពានលើសេរីភាពតាមប្រព័ន្ធអ៊ិនធើណេត

បណ្តាញសង្គមជាមធ្យោបាយដ៏សំខាន់មួយសម្រាប់អ្នកការពារសិទ្ធិមនុស្ស ក្នុងការទាក់ទងនិងបង្ហាញ

ពីការរំលោភបំពានសិទ្ធិនានាជាពិសេសនៅពេលដែលការប្រើប្រាស់ប្រព័ន្ធអ៊ិនធើណេតនៅក្នុងប្រទេសកម្ពុជាកំពុងមានសន្ទុះកើនឡើងយ៉ាងខ្លាំង។ អ្វីដែលជាការរំលោភបំពានដោយផ្ទាល់ទៅលើការបង្ហោះទស្សនៈរិះគន់ គឺជាអំពើនៃការលួចចូលទៅក្នុងគណនីអ៊ីម៉ែល និងក្នុងបណ្តាញសង្គមឯកជនរបស់អ្នកការពារសិទ្ធិមនុស្សល្បីឈ្មោះមួយចំនួន ដោយជនមិនស្គាល់អត្តសញ្ញាណ ចាប់តាំងពីត្រីមាសទីមួយនៃឆ្នាំ២០១៧។ ព្រះតេជព្រះគុណ លួន សុវ៉ាត ជាអ្នកការពារសិទ្ធិមនុស្ស បានប្រើប្រាស់គណនីក្នុងបណ្តាញសង្គមហ្វេសប៊ុកផ្ទាល់របស់ព្រះអង្គ ដើម្បីបង្ហោះនិងចែកចាយវីដេអូនិងរូបភាពដែលព្រះអង្គបានថតនៅពេលមានការតវ៉ានានា ដែលទទួលបានអ្នកគាំទ្រជាង ៦០.០០០នាក់។ បន្ទាប់ពីត្រូវបានគេលួចចូល និងគ្រប់គ្រងគណនីរបស់ព្រះអង្គ គណនីនោះចាប់ផ្តើមបង្ហោះទស្សនៈរិះគន់អសីលធម៌ជាច្រើនលើគណបក្សសង្គ្រោះជាតិដែលជាគណបក្សជំទាស់។ នៅសប្តាហ៍នោះដែរ ចោរប្រព័ន្ធបច្ចេកវិទ្យា (hacker) បានចូលលួចយកគណនីឯកជនក្នុងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រុមមន្ត្រីបក្សជំទាស់ អ្នកសារព័ត៌មាន និងសកម្មជនមួយចំនួន រួមទាំងអ្នកការពារសិទ្ធិមនុស្ស លោក ច័ន្ទ ពុទ្ធិស័ក្ត និងអ្នកស្រី បូរ សោភា ផងដែរ។ ទង្វើនេះ បង្ហាញថាការវាយប្រហារ និងបំភិតបំភ័យតាមប្រព័ន្ធអ៊ិនធើណេត នឹងបង្កើតឥទ្ធិពលអវិជ្ជមានដល់សេរីភាពក្នុងការបញ្ចេញមតិ។ ការកើនឡើងនៃបរិយាកាសភ័យខ្លាច អ្នកការពារនិងសកម្មជនសិទ្ធិមនុស្សមួយចំនួន បានស្ថិតក្រោមការតាមដាន និងបំភិតបំភ័យពីសំណាក់ជនមិនស្គាល់អត្តសញ្ញាណ។

ករណីនេះតែងតែកើតឡើងជារឿយៗនៅក្នុងប្រទេសកម្ពុជា ជាក់ស្តែងដូចជាករណីដែលអ្នកការពារសិទ្ធិមនុស្សមួយចំនួនតែងតែបានទទួលទូរស័ព្ទមិនស្គាល់លេខហៅចូល និងត្រូវបានបុរសមិនស្គាល់អត្តសញ្ញាណមួយចំនួនជិះម៉ូតូតាមពីក្រោយ (នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ការត្រួតពិនិត្យតាមដាននេះ បានកើនឡើងតាមរយៈមធ្យោបាយថ្មីផ្សេងៗ និងធ្ងន់ធ្ងរជាងមុន)។ ក្រុមគ្រួសាររបស់អ្នកការពារសិទ្ធិមនុស្សដ៏ល្បីឈ្មោះមួយចំនួនបច្ចុប្បន្ន កំពុងត្រូវបានរងការបំភិតបំភ័យពីសំណាក់ជនមិនស្គាល់អត្តសញ្ញាណផងដែរ។ ឥឡូវនេះ ការត្រួតពិនិត្យ និង ចាប់ពិរុទ្ធលើអ្នកការពារសិទ្ធិមនុស្សសំខាន់ៗ កាន់តែមានសកម្មភាពញឹកញាប់និងហិង្សាជាងមុន។

អាជ្ញាធរអាចប្រើប្រាស់ការគំរាមកំហែងដោយការថតសំឡេងតាមទូរស័ព្ទ ដែលសកម្មភាពនេះត្រូវបានធ្វើឲ្យទៅជាស្របច្បាប់តាមរយៈច្បាប់ស្តីពីទូរគមនាគមន៍ ប្រសិនបើសកម្មភាពនោះត្រូវបានអនុញ្ញាតដោយ "អាជ្ញាធរស្របច្បាប់" ដែលមិនបានបញ្ជាក់ច្បាស់លាស់នៅក្នុងច្បាប់ ដើម្បីបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស។ ចាប់តាំងពីច្បាប់នេះចូលជាធរមាន ព័ត៌មានទទួលបានពីការថតសំឡេងតាមទូរស័ព្ទ ត្រូវបានគេប្រើប្រាស់នៅក្នុងករណីព្រហ្មទណ្ឌសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងនយោបាយ។

## ការរំលោភបំពានពីសំណាក់អាជ្ញាធរ៖ "យុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅ"

មិនមានអ្វីដែលបង្ហាញយ៉ាងច្បាស់ឲ្យឃើញពីការរឹតត្បិតសេរីភាពជាមូលដ្ឋានជាងសកម្មភាពឆ្លើយតបរបស់អាជ្ញាធររដ្ឋទៅលើការឆ្លើយតបរបស់អាជ្ញាធរទៅលើយុទ្ធនាការអហិង្សា "ថ្ងៃច័ន្ទពណ៌ខ្មៅ" ដែលរៀបចំឡើងដោយក្រុមសង្គមស៊ីវិល ដើម្បីអំពាវនាវសូមឲ្យមានការដោះលែងអ្នកការពារសិទ្ធិមនុស្សដែលជាប់ឃុំទាំងប្រាំនាក់ កាលពីខែឧសភា ឆ្នាំ២០១៦ ធ្វើឲ្យប៉ះពាល់ដល់សេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

ការអនុវត្តបែបអវិជ្ជមានដោយអាជ្ញាធរ ធ្វើឲ្យក្រុមមនុស្សមួយចំនួនត្រូវបានរារាំងមិនឲ្យស្លៀកពាក់ពណ៌ខ្មៅនៅក្នុងយុទ្ធនាការអហិង្សា "ថ្ងៃច័ន្ទពណ៌ខ្មៅ" ឬបង្ហោះព័ត៌មានអំពីយុទ្ធនាការនោះនៅលើបណ្តាញសង្គម។ នៅចុងខែឧសភា រដ្ឋមន្ត្រីក្រសួងការពារជាតិ បានព្រមានប្រើកម្លាំងទ័ពទប់ស្កាត់អ្នកដែលបានចូលរួមនៅក្នុងយុទ្ធនាការអហិង្សា "ថ្ងៃច័ន្ទពណ៌ខ្មៅ" ដោយលោកចាត់ទុកថាជាយុទ្ធនាការ "ខុសច្បាប់"។

កាលពីយុទ្ធនាការលើកទីមួយនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ អ្នកគាំទ្រមួយចំនួនត្រូវបានអាជ្ញាធររារាំង ដោយមិនអនុញ្ញាតឲ្យ ប្រមូលផ្តុំគ្នានៅមុខពន្ធនាគារព្រៃស ម១ និង ម២ ក្នុងរាជធានីភ្នំពេញ ជាកន្លែងដែលអ្នកការពារសិទ្ធិមនុស្សកំពុងជាប់ឃុំ។ ប្រជាពលរដ្ឋចំនួនប្រាំបីនាក់ រួមទាំងសកម្មជនដីធ្លីចំនួនបួននាក់ និងមន្ត្រីសិទ្ធិមនុស្សបួននាក់ (បីនាក់ជាបុគ្គលិកអង្គការលីកាដូ) ត្រូវបានឃាត់ខ្លួនដោយមិនត្រឹមត្រូវ និងត្រូវបានសាកសួរអស់ជាច្រើនម៉ោង មុនពេលដោះលែងអ្នកទាំងនោះមកវិញនៅល្ងាចថ្ងៃដដែល។ ការប្រមូលផ្តុំ ក្នុងយុទ្ធនាការអហិង្សា "ថ្ងៃច័ន្ទពណ៌ខ្មៅ" ក្រោយៗមក មិនសូវបានរៀបចំជាព្រឹត្តិការណ៍ធំនោះទេ៖ សប្តាហ៍ក្រោយៗមក មានករណីឃាត់ខ្លួនមិនត្រឹមត្រូវយ៉ាងតិចចំនួន ៣៨ ដង (ភាគច្រើនជនរងគ្រោះជាស្ត្រីសហគមន៍ដីធ្លី) ដោយអ្នកទាំងនោះគ្រាន់តែស្លៀកសំលៀកបំពាក់ពណ៌ខ្មៅ។ អ្នកការពារសិទ្ធិមនុស្សមួយចំនួន ត្រូវបានឃាត់ខ្លួនអស់រយៈពេលជាច្រើនម៉ោងនៅពេលនោះ ហើយត្រូវបានឲ្យចុះហត្ថលេខាលើកិច្ចសន្យាឈប់ធ្វើការតវ៉ានិងស្លៀកពាក់ពណ៌ខ្មៅ។ ក្នុងអំឡុងពេលយុទ្ធនាការ សូម្បីតែការធ្វើការដុតទៀនដោយអហិង្សាក៏ត្រូវបានអាជ្ញាធរតាមដាន ហើយថែមទាំងទទួលរងការបំបែកដោយកងសន្តិសុខខណ្ឌទៀតផង។

អ្នកតវ៉ាកម្រត្រូវបានអាជ្ញាធរចោទប្រកាន់តាមផ្លូវច្បាប់ (ក្នុងចំណោមការឃាត់ខ្លួនចំនួន ៣៨ លើក ចាប់តាំងពីការចាប់ផ្តើមយុទ្ធនា-ការ មានតែពីរករណីដែលត្រូវបានអាជ្ញាធរចោទប្រកាន់ បើកសវនាការ និងផ្តន្ទាទោស) ប៉ុន្តែវិធីសាស្ត្របំភិតបំភ័យនិងបំបែកការប្រមូលផ្តុំទាំងនេះ គឺជាការព្យាយាមរារាំងអ្នកការពារសិទ្ធិមនុស្សមិនឲ្យចេញមកតាមផ្លូវ ដើម្បីឲ្យសាធារណៈជនបានឃើញ។



អ្នកគាំទ្រយុទ្ធនាការថ្ងៃច័ន្ទព៌ណខ្មៅ បន្ទាប់ពីត្រូវបានដោះលែងពីប៉ុស្តិ៍នគរបាលរាជធានីភ្នំពេញ
ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

# អំពើហិង្សា ដែលគាំទ្រដោយអាជ្ញាធរ

នគរបាល កងសន្តិសុខ និងទាហាន ជាញឹកញយ ត្រូវបានដាក់ពង្រាយដើម្បីរារាំងការប្រមូលផ្តុំដោយ អហិង្សានិងបំបែកអ្នកតវ៉ាហើយអាចភ្ជាប់ជាមួយនូវសកម្មភាពហិង្សាដោយមិនរើសមុខ និងដាក់គោលដៅលើបុគ្គលជាក់លាក់ អាចធ្វើឲ្យរងរបួសទៅលើអ្នកការពារសិទ្ធិមនុស្ស សកម្មជននិង សហជីពមួយចំនួន។

កងសន្តិសុខ បានចេញមុខម្តងហើយម្តងទៀត នៅពេលមានការប្រមូលផ្តុំបញ្ចេញមតិណាមួយជំទាស់នឹងអាជ្ញាធរ។ កងសន្តិសុខដែលប្រដាប់ ដោយដំបង អាចត្រូវបានអាជ្ញាធរប្រើប្រាស់ដើម្បីបំបែក ដោយហិង្សាលើការតវ៉ានានា ហើយច្រើនតែដាក់គោលដៅ ជាក់លាក់លើមេដឹកនាំសហជីព និងក្រុមពលរដ្ឋមូលដ្ឋាន។ ទោះជាកងសន្តិសុខប្រើសកម្មភាពហិង្សាមកលើអ្នកតវ៉ាអហិង្សាក៏ដោយ ក៏មិនទាន់មានកងសន្តិសុខណាម្នាក់ត្រូវបានគេចោទប្រកាន់នៅឡើយទេ។ មិនតែប៉ុណ្ណោះ កងសន្តិសុខទាំងនោះនៅតែអាចប្រព្រឹត្តិអំពើហិង្សាដោយគ្មានការផ្តន្ទាទោសទៀតផង ទោះបីជាមាននគរបាលនៅក្បែរទីនោះក៏ដោយ។

ឧទាហរណ៍ កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ សមាជិកសហជីពយ៉ាងតិចពីរនាក់ បានរងរបួសនៅពេលមានការប្រមូលផ្តុំគ្នានៅក្បែររឹមានរដ្ឋសភាជាតិ ដើម្បីតវ៉ានឹងការអនុម័តច្បាប់ស្តីពីសហជីព ដែលត្រូវបានសភាអនុម័តនាថ្ងៃនោះ។ ការប្រមូលផ្តុំនោះត្រូវបានបំបែកដោយហិង្សាពីសំណាក់កងសន្តិសុខ ហើយនគរបាលដែលឈរក្បែរនោះ មិនបានអន្តរាគមន៍ដើម្បីបញ្ឈប់អំពើហិង្សារបស់កងសន្តិសុខទៅលើសហជីពទេ។

ដោយសារខ្លាចប៉ះពាល់ដល់ផលប្រយោជន៍ឯកជន នគរបាលអន្តរាគមន៍ មិនមានវត្តមាននោះទេនៅពេលអ្នកប្រព្រឹត្តអំពើហិង្សា បានវាយដំលើអ្នកការពារសិទ្ធិមនុស្ស។ ជាក់ស្តែង នៅខែកុម្ភៈ ឆ្នាំ២០១៦ ជម្លោះរវាងនិយោជិតដែលទើបតែបានចូលសហជីព ហើយត្រូវបានបណ្តេញចេញពីការងារ ជាមួយនឹងថៅកែក្រុមហ៊ុនរថយន្តទេសចរណ៍កាពីតូល បានក្លាយជាអំពើហិង្សា នៅពេលដែលការតវ៉ាអហិង្សា របស់ក្រុមនិយោជិតនៅមុខក្រុមហ៊ុនត្រូវបានបំបែកដោយ ហិង្សា ដោយក្រុមសមាជិកសមាគមអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា (CCDA)។ មិនមានសមាជិកណាម្នាក់នៃសមាគមនោះ ត្រូវបានចាប់ខ្លួនក្រោយពេលប្រព្រឹត្តិអំពើហិង្សានោះទេ (សមាជិកមួយចំនួនប្រដាប់ដោយដំបងដែកនិងញញួរ) ប៉ុន្តែជនរងគ្រោះពីរនាក់បែរជាត្រូវបានអាជ្ញាធរចាប់ខ្លួនទៅវិញ ហើយត្រូវបានតុលាការចោទប្រកាន់និងឃុំខ្លួនជិតពីរខែក្នុងពន្ធនាគារ មុនពេលមានការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។ ការវាយប្រហារនេះ គឺបង្ហាញពីការវិវឌ្ឍដ៏គួរឲ្យព្រួយបារម្ភមួយ ព្រោះតែក្រុមអ្នកប្រព្រឹត្តហិង្សាលើក្រុមអ្នកជំទាស់ និងក្រុមសង្គមស៊ីវិលនានា ទទួលបាននិទ្ទណ្ឌភាពស្ទើរតែទាំងស្រុង។



កងសន្តិសុខខណ្ឌវាយប្រហារលើលោក ច័ន្ទ ពុទ្ធិស័ក នៅថ្ងៃប្រារព្ធទិវាសិទ្ធិលំនៅឋានអន្តរជាតិ
ក្នុងរាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦

## អំពើហិង្សាដោយមានគោលដៅ៖ លោក អំ សំអាត និង ច័ន្ទ ពុទ្ធិស័ក

ឧទាហរណ៍អវិជ្ជមានមួយក្នុងចំណោមឧទាហរណ៍អវិជ្ជមានមួយចំនួនទៀតគឺ នៅពេលដែលអ្នកធ្វើការផ្នែកសិទ្ធិមនុស្សដ៏ល្បីឈ្មោះ ដែលជាអ្នកគ្រប់គ្រងផ្នែកឃ្លាំមើល និងជាអ្នកនាំពាក្យរបស់អង្គការ លីកាដូ លោក អំ សំអាត និងតំណាងសហគមន៍បឹងកក់ លោក ច័ន្ទ ពុទ្ធិស័ក កំពុងឃ្លាំមើលក្បួនដង្ហែដោយអហិង្សាដើម្បីប្រារព្ធទិវាសិទ្ធិលំនៅដ្ឋានពិភពលោក អ្នកទាំងពីរត្រូវបានកងសន្តិសុខខណ្ឌវាយដំឲ្យរបួសនៅកណ្តាលរាជធានីភ្នំពេញ។

អំឡុងពេលហែក្បួនអហិង្សានៅក្នុងរាជធានីភ្នំពេញទៅកាន់ទីលានប្រជាធិបតេយ្យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ កងសន្តិសុខបានរារាំងការដើរក្បួននេះ និងបង្កអំពើហិង្សាយ៉ាងធ្ងន់ធ្ងរមកលើលោក ពុទ្ធិស័ក ដែលកំពុងថតសកម្មភាពដើរក្បួន។ បន្ទាប់មក លោក អំ សំអាត បានព្យាយាមបញ្ឈប់អំពើហិង្សាក្រោមអាណត្តិការងាររបស់លោកជាអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សមួយរូប។ ភ្លាមៗនោះ កងសន្តិសុខស្ទុះទៅហ៊ុមព័ទ្ធលោក ហើយបានចាប់ផ្តើមប្រព្រឹត្តិអំពើហិង្សាទៅលើរូបលោក ដោយដាល់មុខលោក និងវាយត្រង់ករបស់លោកជាច្រើនដៃ។ អ្នកទាំងពីរបានរងរបួសហូរឈាម និងត្រូវបាននាំទៅព្យាបាល។

បីខែក្រោយមក ជនរងគ្រោះទាំងពីរត្រូវបានតុលាការកោះហៅឲ្យចូលបំភ្លឺនៅមុខព្រះរាជអាជ្ញាសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ៨ ខែកុម្ភៈ ក្នុងនាមជាជនសង្ស័យនៃបទល្មើស "ហិង្សាដោយចេតនា" ដែលអាចមានទោសជាប់ពន្ធនាគារពីមួយឆ្នាំដល់បីឆ្នាំ។

ទោះជាទទួលបានពាក្យបណ្តឹងជាផ្លូវការមួយចំនួនក៏ដោយ នគរបាលនៅតែមិនទាន់ចាត់វិធានការណាមួយទៅលើកងសន្តិសុខដែលបានបង្កហិង្សានិងដែលគេស្គាល់អត្តសញ្ញាណនោះនៅឡើយ។ អង្គការលីកាដូនិងសារព័ត៌មានជាតិមួយចំនួន មានរូបភាពវីដេអូខ្លីៗជាភស្តុតាង និងមានសាក្សីមួយចំនួនបានឃើញអំពើហិង្សានោះផងដែរ។

## ហិង្សាទៅលើអ្នកគាំទ្រ ដោយសន្តិវិធីអំឡុងពេល សវនាការអ្នកស្រី ទេព វន្នី

នៅខែកុម្ភៈ ឆ្នាំ២០១៧ អំឡុងពេលសវនាការលើសំណុំរឿងអ្នកស្រី ទេព វន្នី ជាអ្នកការពារសិទ្ធិមនុស្សម្នាក់ កងសន្តិសុខបានបំបែកដោយហិង្សាលើក្រុមស្ត្រីនិងកុមារសហគមន៍ដីធ្លីប្រមាណ ៣៥នាក់ ដែលកំពុងអង្គុយនៅក្រៅសាលាដំបូងរាជធានីភ្នំពេញ។ កងសន្តិសុខបានព្យាយាមទាញដោយហិង្សាយកអ្នកគាំទ្រទាំងនោះចេញពីមុខតុលាការ។ នៅពេលដែលអ្នកទាំងនោះបដិសេធដោយមិនចាកចេញ កងសន្តិសុខបានវាយដំលើអ្នកទាំងនោះនិងអូសពួកគេចេញ ដែលបណ្តាលឲ្យស្ត្រីបីនាក់រងរបួស (ស្ត្រីពីរនាក់មកពីសហគមន៍បឹងកក់ និងស្ត្រីម្នាក់ទៀតមកពីសហគមន៍បុរីកីឡា)។

ពលរដ្ឋជាច្រើននាក់បានស្រែកដាក់កងសន្តិសុខ ដោយប្រាប់ឲ្យបញ្ឈប់អំពើហិង្សាលើស្ត្រីទាំងនោះ។ សកម្មជនគណបក្សសង្គ្រោះជាតិម្នាក់ លោក ម៉ៅ សុជាតិ ត្រូវបានកងសន្តិសុខតាមចូលទៅវាយដល់ក្នុងផ្សារទំនើបនៅទល់មុខតុលាការ (ជាលើកដំបូងដែលកងសន្តិសុខបានបង្កអំពើហិង្សានៅក្នុងទីតាំងឯកជន)។ នៅក្នុងផ្សារទំនើបនោះ កងសន្តិសុខបានព័ទ្ធលោកនៅក្បែរហាងលក់ទំនិញ ហើយធាក់និងដាល់លោកជាច្រើនដងលើផ្ទៃមុខនិងក្បាល។



អ្នកគាំទ្រកាន់បដារូប អ្នកស្រី ទេព វន្នី នៅមុខសាលាដំបូង រាជធានីភ្នំពេញ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦

# ការរំលោភបំពានដោយប្រព័ន្ធតុលាការ ៖ ការចោទប្រកាន់ព្រហ្មទណ្ឌលើអ្នករិះគន់

កាលពីឆ្នាំមុនមានករណីអវិជ្ជមានមួយចំនួនទៅលើអ្នកការពារសិទ្ធិមនុស្សដោយអាជ្ញាធរកាន់តែធ្វើការរំលោភបំពានលើអ្នករិះគន់ តាមរយៈការប្រើប្រាស់ប្រព័ន្ធយុត្តាធិការព្រហ្មទណ្ឌ។ យ៉ាងតិចណាស់ មានអ្នកការពារសិទ្ធិមនុស្សចំនួន១២នាក់ ត្រូវបានអាជ្ញាធរចាប់ដាក់ពន្ធនាគារដោយមិនត្រឹមត្រូវក្នុងរយៈពេលពីរឆ្នាំចុងក្រោយ តាមរយៈការប្រើប្រាស់តុលាការដែលមិនឯករាជ្យ ដើម្បីគាបសង្កត់ និងដាក់ទណ្ឌកម្មដល់អ្នកដែលហ៊ាននិយាយជាសាធារណៈអំពីបញ្ហាសិទ្ធិមនុស្ស។ នៅខែឧសភា ឆ្នាំ២០១៧ យ៉ាងតិចមានពលរដ្ឋចំនួន ៧នាក់ កំពុងជាប់ពន្ធនាគារ។

អាជ្ញាធរបានបន្តប្រើប្រាស់មាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌដោយមិនត្រឹមត្រូវ ដើម្បីបំបិទមាត់អ្នកការពារសិទ្ធិមនុស្សមួយចំនួន រាប់តាំងពីការបកស្រាយមិនត្រឹមត្រូវលើភាពស្របច្បាប់ នៃការងារសិទ្ធិមនុស្សថាជាអំពើ "សូកប៉ាន់សាក្សី" រហូតដល់ការចោទប្រកាន់ និងផ្តន្ទាទោសដាក់ពន្ធនាគារ លើអ្នកដែលហ៊ាននិយាយរិះគន់ ដោយផ្អែកលើការចោទប្រកាន់ពីបទញុះញង់ ឬបរិហាកេរ្តិ៍។ ការប្រើប្រាស់ដោយមិនត្រឹមត្រូវនេះ បង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងស្ថាប័នរដ្ឋ និងគណបក្សកាន់អំណាច ហើយនឹងអាចជាការបន្តប្រើប្រាស់ស្ថាប័នទាំងនេះជាឧបករណ៍ ដើម្បីបំភិតបំភ័យនិងរារាំងសកម្មភាពរបស់ក្រុមសង្គមស៊ីវិល។

នៅខែកុម្ភៈ ឆ្នាំ២០១៦ មេដឹកនាំសហជីព និងអ្នកការពារសិទ្ធិមនុស្សដ៏ល្បីឈ្មោះបួនរូប មានលោក អាត់ ធន់ ប្រធានសហព័ន្ធការងារកម្ពុជា CLC លោក គង់ អាទិត្យ អគ្គលេខាធិការសហព័ន្ធការងារកម្ពុជា លោក សុខ ឈុនអឿង ប្រធានសមាគមកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា និង លោក អៀន គីមហុង លេខាធិការសហព័ន្ធកម្មករដឹកជញ្ជូនកម្ពុជា ត្រូវបានអាជ្ញាធរចោទប្រកាន់ពីបទហិង្សាដោយចេតនា រារាំងមន្ត្រីសាធារណៈ និងធ្វើឲ្យកកស្ទះចរាចរណ៍ ពាក់ព័ន្ធនឹងការតវ៉ារបស់បុគ្គលិកក្រុមហ៊ុន កាពីតូល ដែលត្រូវបានក្រុមមនុស្សមិនស្គាល់អត្តសញ្ញាណវាយឲ្យរងរបួស។ បទចោទប្រកាន់ទាំងនេះមិនត្រឹម តែធ្វើឡើងដោយគ្មានមូលដ្ឋានត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែ មនុស្សបីនាក់ក្នុងចំណោមអ្នកទាំងបួនដែលត្រូវបានចោទប្រកាន់មិនបានមានវត្តមាន នៅពេលកើតមានអំពើហិង្សានោះទៀតផង។ មិនតែប៉ុណ្ណោះ អ្នកទាំងនោះនៅតែជាប់បទចោទនេះរហូតមក។ ផ្អែកតាមច្បាប់ស្តីពីសហជីព ការផ្តន្ទាទោសនេះ អាចនឹងត្រូវបានគេប្រើប្រាស់ដើម្បីរារាំងអ្នកទាំងបួនពីការដឹកនាំសហជីពនៅថ្ងៃអនាគត។ នេះអាចជានិន្នាការថ្មីមួយ នៃការប្រើប្រាស់ប្រព័ន្ធយុត្តាធិការព្រហ្មទណ្ឌ ដើម្បីបំបិទចលនាកម្មករ ដោយដាក់គោលដៅ និង ចោទប្រកាន់ដោយមិនត្រឹមត្រូវមកលើមេដឹកនាំសំខាន់ៗ។

បទចោទមួយចំនួន កាន់តែត្រូវបានអាជ្ញាធរប្រើប្រាស់ដោយមិនត្រឹមត្រូវ ដើម្បីចោទប្រកាន់ជាបទព្រហ្មទណ្ឌលើការនិយាយរិះគន់លើអាជ្ញាធរ។ ការចោទប្រកាន់ទាំងនេះ មានឥទ្ធិពលអវិជ្ជមានមកលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពក្នុងការបញ្ចេញមតិ។ ទាំងនេះជាការរំលោភច្បាប់អន្តរជាតិ ដែលតម្រូវឲ្យមានការអត់ធ្មត់ក្នុងកម្រិតមួយទៅលើការបញ្ចេញមតិ។



សកម្មជនដីធ្លី អ្នកស្រី ហង្ស ចិន្តា បានចូលរួមសិក្ខាសាលា នៅក្រុងបាលុង ខេត្តរតនគិរី ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥

នៅខែតុលា ឆ្នាំ២០១៦ អ្នកការពារសិទ្ធិមនុស្ស លោក នី ចរិយា (កំពុងជាប់ពន្ធនាគារបណ្តោះអាសន្នរង់ចាំសវនាការពីបទសូកប៉ាន់សាក្សី) ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារប្រាំមួយខែពីបទ "បរិហារកេរ្តិ៍ជាសាធារណៈ ប្តឹងបរិហារបង្កាច់កេរ្តិ៍ និងផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ" តាមមាត្រា ៣០៥ ៣១១ និង៥២២នៃក្រមព្រហ្មទណ្ឌកម្ពុជា។បទចោទប្រកាន់ទាំងនេះ កើតចេញពីការរិះគន់របស់លោក ចរិយា អំពីរបៀបដែលអាជ្ញាធរ និងសាលាដំបូងខេត្តសៀមរាបដោះស្រាយជម្លោះដីធ្លីមួយ កាលពីឆ្នាំ២០១៥។ លោកបានអំពាវនាវឲ្យមានការស៊ើបអង្កេតលើការឃុំខ្លួនដោយមិនប្រក្រតី និងដោះលែងជនរងគ្រោះនៃការរំលោភសិទ្ធិដីធ្លី (អ្នកដែលតុលាការបានដាក់ឲ្យជាប់ពន្ធនាគារ)។

ការគំរាមកំហែងតាមផ្លូវច្បាប់ ទៅលើសកម្មជនដីធ្លីបានបង្ហាញពីយុទ្ធសាស្ត្រដ៏វែងអន្លាយមួយ៖ កាលពី ខែមីនា ឆ្នាំ២០១៥ សកម្មជនដីធ្លីពីររូបគឺ អ្នកស្រី ហង្ស ចិន្តា និងអ្នកស្រី ហង្ស សុភាព ដែលជាតំណាងប្រជាពលរដ្ឋ ២៤គ្រួសារ ជាប់ពាក់ព័ន្ធនឹងករណីជម្លោះដីធ្លីមួយតាំងពីឆ្នាំ១៩៩៦ ត្រូវបានព្រះរាជអាជ្ញាខេត្តព្រះសីហនុកោះហៅទៅបំភ្លឺ ខណៈដែលអ្នកទាំងនោះកំពុងបន្តយុទ្ធនាការទាមទារដីធ្លីមកវិញ។ អ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទប៉ះពាល់កម្មសិទ្ធិឯកជន យោងតាមមាត្រា២៤៨ និងមាត្រា ២៥៣ នៃច្បាប់ភូមិបាលនៃព្រះរាជាណាចក្រ កម្ពុជា។

ការប្រើប្រាស់ស្ថាប័នយុត្តិធម៌របស់កម្ពុជា ដើម្បីចោទប្រកាន់បទព្រហ្មទណ្ឌលើអ្នកការពារសិទ្ធិមនុស្ស មិនត្រឹមតែបង្អាក់ការធ្វើសកម្មភាពក្នុងការការពារសិទ្ធិមនុស្សដោយស្របច្បាប់ប៉ុណ្ណោះទេ គឺថែមទាំងបំបាក់ភាពជាអ្នកដឹកនាំដែលសហគមន៍ងាយរងគ្រោះត្រូវការជាចាំបាច់និងនាំឲ្យមានការស្តីបន្ទោសទម្លាក់កំហុសលើខ្លួនឯងទៀតផង។

# ការចោទប្រកាន់ព្រហ្មទណ្ឌលើអ្នកធ្វើការងារសិទ្ធិមនុស្ស៖ ”មន្ត្រីអាដហុកទាំង៥”

**"យើងទាំងអស់គ្នានៅតែជាអ្នកការពារសិទ្ធិមនុស្ស។ ការងារដំបូងដែលខ្ញុំនឹងធ្វើ នឹងបន្តការងារសិទ្ធិមនុស្សរបស់ខ្ញុំ។"**

***(លោក យី សុខសាន្ត នៅថ្ងៃដែលត្រូវបានគេ ដោះលែង ពីពន្ធនាគារ ក្នុងខែមិថុនា ឆ្នាំ២០១៧)***

កាលពីខែមេសាឆ្នាំមុន អ្នកការពារសិទ្ធិមនុស្សទាំងប្រាំនាក់ ត្រូវបានអាជ្ញាធរឃុំខ្លួនក្នុងពន្ធនាគារ នៅពេលដែលការងារសិទ្ធិមនុស្សស្របច្បាប់របស់អ្នកទាំងនោះ ត្រូវបានអាជ្ញាធរប្រើប្រាសជាមូលហេតុ ដើម្បីចោទប្រកាន់ដោយមិនត្រឹមត្រូវលើពួកគេពីបទល្មើសសូកប៉ាន់សាក្សី។

លោកនី សុខា លោក ណៃ វ៉ង់ដា លោក យី សុខសាន្ត និងអ្នកស្រី លឹម មុន្នី ជាបុគ្គលិកសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) និងលោក នី ចរិយា ជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជាអតីតបុគ្គលិកអង្គការអាដហុក ផងដែរ ត្រូវបានអាជ្ញាធរសួរចម្លើយ និងឃុំខ្លួន បន្ទាប់ពីមាន “ការស៊ើបអង្កេត” ដោយអង្គភាពប្រឆាំងអំពើពុករលួយ ពាក់ព័ន្ធនឹង រឿងក្តី អតីតអនុប្រធានគណៈបក្សជំទាស់ ឯកឧត្តម កឹម សុខា។
ទីបំផុតអ្នកទាំងប្រាំត្រូវបានតុលាការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំសវនាការ ក្នុងខែមិថុនា ឆ្នាំ២០១៧ បន្ទាប់ពីបានជាប់ឃុំឃាំងក្នុងពន្ធនាគារអស់រយៈពេលជាងមួយឆ្នាំ។ អ្នកទាំងនោះនៅតែរង់ចាំការបើកសវនាការលើសំណុំរឿងរបស់ពួកគេទាក់ទងនឹងបទចោទប្រកាន់ជាច្រើន ដែលត្រូវបានថ្កោលទោសពីសំណាក់សាធារណជន ជាតិ និងអន្តរជាតិ អ្នកការទូត និងអង្គការសហប្រជាជាតិ។

នៅក្នុងការស៊ើបអង្កេតបឋមក្នុងរឿងក្តីនេះ ការចូលរួមរបស់នគរបាលប្រឆាំងភេរវកម្មអាចបង្ហាញពីការកើនឡើងនៃការភ្ជាប់សកម្មភាពការពារសិទ្ធិមនុស្ស ទៅនឹងសកម្មភាពគំរាមកំហែងដល់សន្តិសុខជាតិ និងអាជ្ញាធរ។ កាលពីខែមេសា ឆ្នាំ២០១៧ ក្រសួងការបរទេសកម្ពុជា បានចេញផ្សាយលិខិតមួយកម្រាស់ ១១ ទំព័រ ដែលមានចំណងជើងថា "បកស្រាយការពិត" ដែលជាការឆ្លើយតបទៅលើការរិះគន់ក្នុងស្រុកនិងអន្តរជាតិ លើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ថាជា "យុទ្ធនាការមួយបង្កឡើងដោយអង្គការនិងរដ្ឋាភិបាលបរទេស ដើម្បីចង់ឲ្យមានការផ្លាស់ប្តូររបបនៅកម្ពុជា" ដោយបានអះអាងថាយុទ្ធនាការនេះ គឺ "បញ្ឆេះដោយកែប្រែការពិត ការភូតកុហក បំប៉ោងព័ត៌មាន" ដើម្បី "បន្ទាប និងបន្ទោសលើស្ថាប័នស្របច្បាប់ និងដែលមានស្រាប់"។[៣] ការចាត់ទុកសកម្មភាពសិទ្ធិ-មនុស្សស្របច្បាប់ ថាជាអំពើព្រហ្មទណ្ឌបែបនេះ បានផ្តល់ផលវិបាកជាច្រើន មិនត្រឹមតែដល់អ្នកការពារសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក៏អាចប៉ះពាល់ដល់ប្រព័ន្ធនីតិរដ្ឋនៅកម្ពុជាផងដែរ។

អ្នកទាំងប្រាំនាក់ បានជាប់ពន្ធនាគារយូរជាងសមាជិកកងអង្គរក្សរបស់សម្តេចនាយករដ្ឋមន្ត្រីទៅទៀត។ កងអង្គរក្សទាំងនោះត្រូវបានផ្តន្ទាទោសពីបទហិង្សាដោយចេតនា ដែលបានប្រព្រឹត្តលើតំណាងរាស្ត្រគណបក្សជំទាស់ពីររូប នៅក្រៅរបងវិមានរដ្ឋសភាជាតិ អំឡុងពេលមានការតវ៉ាប្រឆាំងលោក កឹម សុខា កាលពីខែតុលា ឆ្នាំ២០១៥។ កងអង្គរក្សទាំងនោះ ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលបួនឆ្នាំ ប៉ុន្តែបីភាគបួននៃទោសរបស់អ្នកទាំងនោះត្រូវបានព្យួរ ហើយឥឡូវអ្នកទាំងនោះបានចេញពីពន្ធនាគារហើយ ក្រោយអនុវត្តទោសបានរយៈពេលមួយឆ្នាំ។



លោក នី ចរិយា ខណៈពេលជួបជាមួយកូនស្រីរបស់លោក នៅតុលាការកំពូល ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

[៣] Cambodian Ministry of Foreign Affairs, ‘Cambodia, Democracy and Human Rights: To Tell the Truth’ https://www.mfaic.gov.kh/site/detail/9842

# ការចោទប្រកាន់ព្រហ្មទណ្ឌលើអ្នកតវ៉ាអហិង្សា៖ ការចោទប្រកាន់ តាមរយៈ ប្រព័ន្ធតុលាការ លើអ្នកស្រី ទេព វន្នី ដោយគ្មានមូលដ្ឋាន ច្បាស់លាស់

**"យើងមិនខ្លាចទេគុកច្រវាក់។ យើងធ្លាប់ជាប់ពីមុនមកហើយ។ ប៉ុន្តែយើងត្រូវការសេរីភាព ដូចនេះ យើងនៅតែបន្តតស៊ូដើម្បីយុត្តិធម៌"**

***(ដោយអ្នកស្រី ទេព វន្នី ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧)***

ជាការឆ្លើយតបទៅនឹងការជាប់ពន្ធនាគាររបស់អ្នកការពារសិទ្ធិមនុស្សទាំងប្រាំនាក់ ក្រុមសង្គម ស៊ីវិល បានរៀបចំយុទ្ធនាការអហិង្សា "ថ្ងៃច័ន្ទពណ៌ ខ្មៅ" ដើម្បីអំពាវនាវឲ្យមានការដោះលែងអ្នកទាំងនោះ។ ចាប់តាំងពីការចាប់ផ្តើមមក អាជ្ញាធរបានធ្វើការបង្ក្រាបដោយមិនត្រឹមត្រូវមកលើយុទ្ធនាការ អហិង្សានេះ។ កាលពីថ្ងៃទី ១៥ ខែសីហា អ្នកស្រី ទេព វន្នី និងអ្នកស្រី បូវ សោភា មកពីសហគមន៍បឹង កក់ ត្រូវបានចាប់ខ្លួនអំឡុងពេលរៀបចំយុទ្ធនាការ អហិង្សា "ថ្ងៃច័ន្ទពណ៌ខ្មៅ" នៅក្នុងសហគមន៍របស់ អ្នកទាំងពីរ។ រូបភាព វីដេអូ បង្ហាញថាអ្នកទាំងពីរត្រូវបានដាក់គោលដៅ និងចាប់ខ្លួនដោយកងសន្តិសុខខណ្ឌ។ ក្នុងរយៈពេលមួយសប្តាហ៍ អ្នកទាំងពីរត្រូវបានផ្តន្ទាទោសពីបទ "ជេរប្រមាថ" តាមមាត្រា៥០២ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងផ្តន្ទាទោសឲ្យជាប់ពន្ធនា-គាររយៈពេលប្រាំមួយថ្ងៃ បន្ទាប់ពីបានបើកសវនាការមួយដែលរំលោភលើសិទ្ធិមួយចំនួនក្នុងការទទួលបានយុត្តិធម៌។

នេះគ្រាន់តែជាលេសនៃការចាប់ផ្តើមការបង្ក្រាបរបស់អាជ្ញាធរទៅលើសកម្មជនដីធ្លី និងជាអ្នកការពារសិទ្ធិមនុស្សល្បីឈ្មោះ អ្នកស្រី ទេព វន្នី តែប៉ុណ្ណោះ។ កាលពីថ្ងៃទី ១៩ ខែសីហា នៅពេល  អ្នកស្រីកំពុងជាប់ពន្ធនាគារបណ្តោះអាសន្នរង់ចាំ សវនាការ សំណុំរឿងពីរផ្សេងទៀតពាក់ព័ន្ធនឹងការ តវ៉ារបស់សហគមន៍បឹងកក់ កាលពីឆ្នាំ២០១១ និង ឆ្នាំ២០១៣ ត្រូវបានតុលាការលើកយកមកជំនុំជម្រះឡើងវិញ ដើម្បីផ្តន្ទាទោសលើអ្នកស្រីបន្ថែមទៀត។

នៅខែតុលា ឆ្នាំ២០១៦ អ្នកស្រី វន្នី រួមជាមួយតំណាងសហគមន៍បឹងកក់បីនាក់ផ្សេងទៀត ត្រូវបានតុលាការបើកសវនាការ និងផ្តន្ទាទោសពីបទរារាំងមន្ត្រីរាជការសាធារណៈដោយមានស្ថានទម្ងន់ទោស នៅក្នុងសំណុំរឿងការតវ៉ាដីធ្លីរបស់សហគមន៍បឹងកក់ កាលពីឆ្នាំ២០១១។ អ្នកទាំងបួន ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ៦ខែ។ កាលពីខែកុម្ភៈ ឆ្នាំ២០១៧ បន្ទាប់ពីជាប់ឃុំ បណ្តោះអាសន្នរយៈពេល ៦ខែ អ្នកស្រី វន្នី ក៏ត្រូវបានតុលាការបើកសវនាការលើសំណុំរឿងដែលនៅសល់មួយទៀតពីបទ "ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស" ពាក់ព័ន្ធនឹងការតវ៉ាសុំឲ្យដោះលែងតំណាងសហគមន៍បឹងកក់ អ្នកស្រី យ៉ោម បុប្ផា កាលពីឆ្នាំ២០១៣។ បីសប្តាហ៍ក្រោយមក អ្នកស្រី ត្រូវបានតុលាការប្រកាសសាលក្រមផ្តន្ទាទោសពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងដាក់ឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំនិងប្រាំមួយខែ។ អ្នកស្រី មិនបានចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ នោះទេ ហើយអ្នកស្រីអាចត្រូវជាប់ក្នុងពន្ធនាគាររហូតដល់ក្រោយការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨



អ្នកស្រី ទេព វន្នី មុនពេលគាត់ត្រូវបានចាប់ខ្លួន ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

## ច្បាប់ថ្មីដែលមានលក្ខណៈរឹតត្បិត

អាជ្ញាធរអាចបង្ហាញនូវបំណង និងអំណាចក្នុងការប្រើប្រាស់ដោយមិនត្រឹមត្រូវនូវច្បាប់ដែលមានស្រាប់ ដើម្បីចោទប្រកាន់លើអ្នកការពារសិទ្ធិមនុស្ស។ ប៉ុន្តែនៅរយៈពេលពីរឆ្នាំចុងក្រោយនេះ ច្បាប់ថ្មីមួយចំនួនដែលមានលក្ខណៈរឹតត្បិតត្រូវបានសភាអនុម័ត និងវិសោធនកម្មច្បាប់ចាស់ត្រូវបានធ្វើឡើង ដើម្បីដាក់គោលដៅទៅលើអ្នកការពារសិទ្ធិមនុស្ស។ បរិយាកាសសម្រាប់ សង្គមស៊ីវិល សិទ្ធិមនុស្ស និងប្រជាពលរដ្ឋ ត្រូវបានរឹតត្បិត ខណៈពេលដែលអាជ្ញាធរកំពុងពង្រឹងអំណាច នៅក្នុងបរិបទសាធារណៈ និងឯកជន ដែលនេះអាចនាំឲ្យមានការព្រួយបារម្ភ នៅមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងការបោះឆ្នោតថ្នាក់ជាតិខាងមុខ។

នៅក្នុងច្បាប់ថ្មីមួយចំនួន មានចែងនូវមាត្រាជាច្រើនដែលមានលក្ខណៈបំភិតបំភ័យនិងគំរាមកំហែងដល់បុគ្គល និងក្រុមការពារសិទ្ធិមនុស្ស ដែលហ៊ានបញ្ចេញមតិ។

**ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា**
ត្រូវបានអនុម័តកាលពីឆ្នាំ២០១៤ ដោយផ្តល់សិទ្ធិស្របច្បាប់ និងពង្រឹងការគ្រប់គ្រងនៃអំណាចនីតិប្រតិបត្តិមកលើអង្គតុលាការនិងអយ្យការ ដែលមិនស្របពីគោលការណ៍នីតិរដ្ឋ ជាពិសេសនៅក្នុងសំណុំរឿងអ្នកការពារសិទ្ធិមនុស្ស ដែលអាចមានលក្ខណៈជាប់ពាក់ព័ន្ធនឹងនយោបាយ។

**ច្បាប់ស្តីពីអង្គការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ត្រូវបានអនុម័តកាលពីឆ្នាំ២០១៥ ដោយមានមាត្រាមួយចំនួនមានលក្ខណៈគំរាមកំហែងដល់ក្រុមសង្គមស៊ីវិល។ ច្បាប់នេះ អាចនឹងត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងព្យាយាមបំភិតបំភ័យអង្គការសង្គមស៊ីវិលមួយចំនួន ដើម្បីរារាំងសកម្មភាពអង្គការទាំងនោះពីការអនុវត្តការងារសិទ្ធិមនុស្សដោយស្របច្បាប់។ កាលពីខែមេសា ឆ្នាំ២០១៧ ក្រសួងមហាផ្ទៃបានដាក់ពាក្យបណ្តឹងមួយពាក់ព័ន្ធនឹងសហជីពឯករាជ្យលេចធ្លោមួយគឺ សមាគមគ្រូបង្រៀនឯករាជ្យ (CITA) ដោយបានអះអាងថាការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់សមាគមនេះ គឺផ្ទុយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ**
ត្រូវបានសភាជាតិធ្វើវិសោធនកម្មកាលពីឆ្នាំ ២០១៥។ វិសោធនកម្មច្បាប់នេះ ត្រូវបានធ្វើឡើងជាផ្នែកមួយនៃកិច្ចចរចានយោបាយរវាងគណបក្សធំពីរ ដែលមានការពិន័យជាប្រាក់ និងហាមឃាត់អង្គការមិនមែនរដ្ឋាភិបាលណាដែលរិះគន់គណបក្សនយោបាយអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតរយៈពេល ២១ថ្ងៃ។ ជាងនេះទៅទៀត ច្បាប់នេះបានហាមឃាត់ការចូលរួមរបស់ក្រុមសង្គមស៊ីវិលក្នុងដំណើរការនៃការបោះឆ្នោត ដែលនេះជាភាពអន់ថយមួយនៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ ការធ្វើវិសោធនកម្មដូចគ្នានេះ ត្រូវបានធ្វើឡើងចំពោះច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ផងដែរ។

**ច្បាប់ស្តីពីសហជីព** បានផ្តល់សិទ្ធិឲ្យអាជ្ញាធររដ្ឋមានអំណាចគ្រប់គ្រងលើអត្ថិភាព និងឯករាជ្យភាពរបស់សហជីព។ ច្បាប់នេះ ក៏អនុញ្ញាតឲ្យធ្វើការកត់ត្រាចូលបញ្ជីខ្មៅនូវសហជីពណា ដែលទទួលបានការផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ដែលអាចមានលក្ខណៈនយោបាយ រួមទាំងអ្នកការពារសិទ្ធិមនុស្សមួយចំនួន ដែលត្រូវបានអាជ្ញាធរដាក់គោលដៅដោយសារការងារសហជីពរបស់អ្នកទាំងនោះ។

**ច្បាប់ស្តីពីប្រព័ន្ធទូរគមនាគមន៍** ដែលត្រូវបានអនុម័តកាលពីឆ្នាំ២០១៦ អនុញ្ញាតឲ្យអាជ្ញាធរធម្មានរូបអាចត្រួតពិនិត្យចាប់ពិរុទ្ធជាសាកល និងធ្វើការដាក់ទោសលើការបញ្ចេញមតិដោយសេរី ប្រសិនបើអាជ្ញាធរគិតថាសកម្មភាពនោះជាការគំរាមកំហែងដល់ពួកគេ។ បច្ចេកវិទ្យាទូរគមនាគមន៍ បានបង្កើនសំឡេងអ្នកការពារសិទ្ធិមនុស្ស និងជួយដល់អ្នកទាំងនោះក្នុងការបង្ហាញអំពីការរំលោភសិទ្ធិមនុស្ស ប៉ុន្តែច្បាប់នេះអាចនឹងត្រូវបានអាជ្ញាធរប្រើប្រាស់ ដើម្បីជ្រៀតជ្រែកលើសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សក្នុងការទាក់ទងគ្នាដោយសុវត្ថិភាព និងការបង្ហាញឲ្យដឹងឮអំពីការរំលោភសិទ្ធិមនុស្ស។ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធើណេតទាំងនេះ ដោយផ្អែកលើពាក្យ "សន្តិសុខជាតិ" ដែលមានន័យមិនច្បាស់លាស់ អាចនឹងត្រូវបានបកស្រាយមិនត្រឹមត្រូវ ដោយប្រព័ន្ធយុត្តាធិការដែលអាចមានលក្ខណៈនយោបាយនៅក្នុងប្រទេសកម្ពុជា។

សេចក្តីព្រាងច្បាប់ដែលមានលក្ខណៈរឹតត្បិតមួយចំនួនទៀត កំពុងត្រូវបានធ្វើឡើង ប៉ុន្តែមិនទាន់បានអនុម័តនៅឡើយទេ។

**ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា** ដែលនឹងត្រូវព្រាងបញ្ចប់នៅចុងឆ្នាំ២០១៧ អាចផ្តល់អំណាចឲ្យអាជ្ញាធរ ដែលនឹងផ្តល់ផលវិបាកជាច្រើនដល់សេរីភាពក្នុងការបញ្ចេញមតិ ការប្រមូលផ្តុំ និងការជួបជុំរបស់សហជីព កម្មករ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋដែលតស៊ូមតិដើម្បីទទួលបានប្រាក់ឈ្នួលអប្បបរមាសមរម្យ។ សេចក្តីព្រាងច្បាប់មួយចំនួនទៀតដែលពាក់ព័ន្ធនឹងការងារដូចជាសេចក្តីព្រាងច្បាប់ស្តីពីការដោះស្រាយវិវាទការងារ អាចគំរាមកំហែងដល់អង្គការរបស់កម្មករដែលឯករាជ្យ ហើយអាចពង្រឹងអំណាចនយោបាយទៅលើការដោះស្រាយវិវាទការងារ។

**ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម** មានលក្ខណៈគាបសង្កត់ និងបង្កើតឲ្យមានរបបដីសម្បទានសេដ្ឋកិច្ចដែលអាចមានលក្ខណៈអវិជ្ជមាន ហើយរបបទណ្ឌកម្មរដ្ឋបាលរបស់ច្បាប់នេះ ក៏អាចនឹងត្រូវបានអនុវត្តដើម្បីដាក់ទណ្ឌកម្មដល់ជនរងគ្រោះពីការរំលោភសិទ្ធិដីធ្លី ដោយការបកស្រាយមិនត្រឹមត្រូវនូវមាត្រាមួយចំនួនដែលចែងមិនច្បាស់លាស់។

**ច្បាប់ស្តីពីឧក្រិដ្ឋកម្មព័ត៌មានវិទ្យា** ដែលមានលក្ខណៈរឹតត្បិតក៏នឹងត្រូវអនុម័តផងដែរ។

ច្បាប់ទាំងអស់នេះ នឹងធ្វើឲ្យមានការរឹតត្បិតយ៉ាងខ្លាំងដោយមិនត្រឹមត្រូវលើសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបជុំដោយសន្តិវិធី។ ប្រសិនបើច្បាប់ទាំងនេះមិនត្រូវបាននិរាករណ៍ទេ ច្បាប់ទាំងនេះអាចនឹងបំបិទសំឡេងអ្នកធ្វើការងារ អ្នកធ្វើយុទ្ធនាការ មេធាវី អ្នកសារព័ត៌មាន សហជីព មេដឹកនាំសហគមន៍ជនបទនិងទីក្រុង និងប្រជាពលរដ្ឋ។

# ឃាតកម្មលើបណ្ឌិត កែម ឡី

**"ជូនទឹកភ្នែក រួចបន្តដំណើរទៅមុខទៀត"**

នៅខណៈដែលមានការកើនឡើងនូវការរឹតត្បិតពីអាជ្ញាធរលើអ្នករិះគន់ បុគ្គលម្នាក់បានចំណាយតម្លៃមួយដែលមិនអាចកាត់ថ្លៃបាន ក្នុងការបញ្ចេញមតិរិះគន់របស់លោក។ កាលពីថ្ងៃទី ១០ ខែកក្កដា អ្នកវិភាគសង្គមនិងនយោបាយដ៏លេចធ្លោ លោកបណ្ឌិត កែម ឡី ត្រូវបានគេបាញ់សម្លាប់នៅកណ្តាលថ្ងៃត្រង់និងនៅកណ្តាលរាជធានីភ្នំពេញ ខណៈដែលលោកកំពុងពិសារកាហ្វេនៅក្នុងហាងក្បែរស្ថានីយ៍ប្រេងឥន្ធនៈមួយកន្លែង។

មរណៈភាពរបស់លោកធ្វើឲ្យមានការភ្ញាក់ផ្អើលពេញមួយប្រទេស។ ភ្លាមៗនៃអំពើឃាតកម្ម ចំនួនប្រជាពលរដ្ឋប្រមូលផ្តុំគ្នាបានកើនឡើងភ្លាមៗនៅស្ថានីយ៍ប្រេងឥន្ធនៈ ជាកន្លែងដែលសាកសពរបស់លោកស្ថិតនៅបន្ទាប់ពីការបាញ់ប្រហារនោះ។ ប៉ុន្មានម៉ោងក្រោយមក ប្រជាពលរដ្ឋរាប់ពាន់នាក់បានចាប់ផ្តើមដង្ហែសពរបស់លោកទៅកាន់វត្តចាស់នៅក្នុងរាជធានីភ្នំពេញ។ នៅពេលប្រជាពលរដ្ឋទៅដល់វត្តចម្ងាយប្រមាណជាប្រាំពីគីឡូម៉ែត ក្បួនបានរីកធំទៅៗរហូតដល់ប្រមាណ ៥.០០០នាក់ រួមមានទាំងព្រះសង្ឃ និងសមាជិកសហគមន៍នានាក្នុងទីក្រុង។ នៅពីរសប្តាហ៍ក្រោយមក ប្រជាពលរដ្ឋរាប់រយពាន់នាក់បានចូលរួមដង្ហែសពរបស់លោក។

ជនសង្ស័យម្នាក់ដែលត្រូវបានគេស្គាល់ថា "ជួបសម្លាប់" ត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីឃាតកម្មលើលោកបណ្ឌិត កែម ឡី។ ជននោះបានសារភាពថា ខ្លួនជាអ្នកបាញ់សម្លាប់លោកបណ្ឌិត ដោយសារលោកបណ្ឌិតជំពាក់ប្រាក់ ៣០០០ដុល្លារ។ ការអះអាងនេះត្រូវបានច្រានចោលដោយសារធារណៈជន ព្រោះ ការអះអាងនេះមិនសមហេតុផល។ ទោះបីជាមានចន្លោះប្រហោងមួយចំនួននៅក្នុងសំណុំរឿងនេះ រួមទាំងត្រូវបានមតិជាតិនិងអន្តរជាតិអះអាងថា មិនទាន់បានធ្វើការស៊ើបអង្កេតពេញលេញលើអង្គហេតុ អ្នកសមគំនិត និងស្ថានភាពជុំវិញការចាប់ខ្លួនជននោះក៏ដោយ ក៏លោក ជួប សម្លាប់ ឈ្មោះពិត អឿត អាង ត្រូវបានតុលាការផ្តន្ទាទោសពីបទមនុស្សឃាតគិតទុកជាមុនកាលពីខែកុម្ភៈ ឆ្នាំ២០១៧។




ពិធីដង្ហែសពលោកបណ្ឌិត កែម ឡី ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦



សហគមន៍ចូលរួមប្រារព្ធទិវាសិទ្ធិលំនៅឋានអន្តរជាតិ នៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦

## ការបំបិទសំឡេងអ្នករិះគន់

ស្របពេលដែលមានការរិះគន់ថា អាជ្ញាធរមិនបានខិតខំធ្វើការស៊ើបអង្កេតឲ្យពេញលេញលើសំណុំរឿងឃាតកម្មលើលោកបណ្ឌិត កែម ឡី អាជ្ញាធរក៏តែងតែបំបិទការនិយាយ និងការបញ្ចេញមតិពាក់ព័ន្ធនឹងសំណុំរឿងនេះដែរ។ លោក គឹម សុខ អ្នកវិភាគនយោបាយជំនាន់ក្រោយមួយរូបទៀត កំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ ក្រោមបទចោទបរិហារកេរ្តិ៍ និងញុះញង់ចំពោះសកម្មភាពរបស់លោក ក្នុងការធ្វើបទអធិប្បាយក្នុងកិច្ចសម្ភាសន៍មួយជាមួយវិទ្យុអាស៊ីសេរីពាក់ព័ន្ធនឹងសំណុំរឿងឃាតកម្មលើលោកបណ្ឌិត កែម ឡី នោះ។

កាលពីថ្ងៃទី ១២ ខែមិនា យុវជនបួននាក់ ត្រូវបានគេចាប់ខ្លួននិងឃាត់ខ្លួនរយៈពេលខ្លី នៅពេលដែលនគរបាលនិងកងសន្តិសុខខណ្ឌប្រមាណ ៤០នាក់ បានហាមឃាត់ដោយមិនឲ្យចាក់បញ្ចាំងវីដេអូឯកសារឃាតកម្ម លើលោកបណ្ឌិត កែម ឡី របស់សារព័ត៌មានបរទេស Al Jazeera ជាលក្ខណៈឯកជន ដែលវីដេអូនេះត្រូវបានគេផ្សព្វផ្សាយជាសាធារណៈនៅលើប្រព័ន្ធអ៊ិនធើណេត តាំងពីប៉ុន្មានខែមុនមកម្ល៉េះ។ ការចាក់បញ្ចាំងនេះ គ្រោងនឹងត្រូវបានធ្វើឡើងនៅក្នុងការិយាល័យឯកជន របស់សមាគមសម្ព័ន្ធបញ្ញាវ័ន្តនិស្សិតកម្ពុជា។ យុវជនទាំងអស់ ត្រូវបានដោះលែងមកវិញនៅបីម៉ោងក្រោយមក បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចសន្យាថា នឹងមិនចាក់បញ្ចាំងឯកសារនេះទៀតបើមិនមានការអនុញ្ញាតពីអាជ្ញាធរនោះទេ។

សកម្មភាពទាំងនេះ បង្កជាការព្រួយបារម្ភជាខ្លាំងចំពោះបុគ្គលដែលចង់អនុវត្តសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការសម្ដែងមតិ គំនិត ការប្រមូលផ្ដុំ និងការជួបជុំដោយអហិង្សា នៅអំឡុងពេលនៃការបោះឆ្នោត។

# ការតវ៉ា និងការតស៊ូដោយអហិង្សា ៖ ក្តីសង្ឃឹមសម្រាប់អនាគត

ប្រទេសកម្ពុជាបច្ចុប្បន្នកំពុងស្ថិតនៅចំណុចសំខាន់មួយនៃដំណើរវិវឌ្ឍន៍របស់ខ្លួន។ ទោះបីជាមានព្រឹត្តិការណ៍តក់ស្លុតនៃឃាតកម្មលោកបណ្ឌិត កែម ឡី ក៏ដោយ ក៏នៅឃើញមានប្រជាពលរដ្ឋរាប់រយពាន់នាក់ ចេញមកចូលរួមដង្ហែក្បួនទាមទារឲ្យស្វែងរកយុត្តិធម៌ ដល់សពលោកបណ្ឌិត ផងដែរ។ នេះសបញ្ជាក់នូវសញ្ញានៃភាពតស៊ូអហិង្សា និងវត្តមានយ៉ាងស្វិតស្វាញនៃក្រុមសង្គមស៊ីវិលកម្ពុជា និងអ្នកការពារសិទ្ធិមនុស្សនានា ក្នុងការប្រឈមមុខនឹងការបំភិតបំភ័យ ការជាប់ពន្ធនាគារ និងអំពើហិង្សាមួយចំនួន។

នៅមុនពេលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អាជ្ញាធរបានបង្កើនសកម្មភាពអវិជ្ជមានទៅលើការអនុវត្តសិទ្ធិ និងសេរីភាពអហិង្សានានារបស់សង្គមស៊ីវិល។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ អ្នកដែលហ៊ានចេញតវ៉ាដើម្បីសិទ្ធិមនុស្ស អាចប្រឈមមុខនឹងច្បាប់ដែលមានលក្ខណៈរឹតត្បិត ការបំភិតបំភ័យដោយប្រព័ន្ធច្បាប់ និងប៉ះពាល់លើការអនុវត្តសេរីភាពជាមូលដ្ឋាន ក្នុងគោលបំណងបង្កើតឲ្យមានបរិយាកាសភ័យខ្លាច និងស្ងប់ស្ងាត់ ដោយកាត់បន្ថយសំឡេងរិះគន់នានា។ ការប្រមូលផ្តុំដោយសន្តិវិធី មួយចំនួន ត្រូវបានចាត់ទុកថាជា បដិវត្តន៍ និងត្រូវបានហាមឃាត់ ហើយតែងតែត្រូវបានបង្ក្រាបដោយហិង្សា។

ប៉ុន្តែសកម្មភាពទាំងនេះ មិនបានបញ្ឈប់ការតវ៉ាដែលកើតឡើងស្ទើរតែរាល់ថ្ងៃនោះទេ មិនថានៅក្នុងទីក្រុង ឬនៅតាមបណ្តាខេត្តទេ ប្រជាពលរដ្ឋមិនដែលបោះបង់ចោលការតវ៉ាទាមទារដោយអហិង្សាឲ្យគោរពសិទ្ធិដីធ្លី ឬសិទ្ធិនយោបាយរបស់អ្នកទាំងនោះឡើយ។ ទោះបីជាអាជ្ញាធរព្យាយាមបន្ថយសំឡេងរបស់ប្រជាពលរដ្ឋទាំងនោះក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជានៅតែបន្តទាមទារដោយអហិង្សាឲ្យអាជ្ញាធរដឹងឮនូវបញ្ហារបស់ពួកគេដដែល។

នៅខណៈដែលការបោះឆ្នោតជាតិខិតជិតមកដល់ ការងាររបស់អ្នកការពារសិទ្ធិមនុស្សមកពីគ្រប់វិស័យក្នុងសង្គមនឹងកាន់តែមានសារសំខាន់ថែមទៀត។ ទោះបីជាអាជ្ញាធរ អាចមិនបន្តគោរពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនៅក្នុងការបោះឆ្នោតខាងមុខក៏ដោយ ក៏នៅតែមានការតស៊ូ សាមគ្គីភាព និងការអំពាវនាវសារជាថ្មីឲ្យមានភាពយុត្តិធម៌សម្រាប់អ្នកការពារសិទ្ធិមនុស្ស និងអ្នកដែលហ៊ានក្រោកឈរតវ៉ាផ្សេងៗនៅក្នុងប្រទេសកម្ពុជា។



សហគមន៍អំពាវនាវឲ្យមានការដោះលែងសកម្មជនមាតាធម្មជាតិ ដែលកំពុងជាប់ឃុំ ក្នុងខេត្តកោះកុង ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥

# អនុសាសន៍

**យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលនិងអាជ្ញាធរកម្ពុជា លោកនឹងៈ**

►► ដោះលែងអ្នកការពារសិទ្ធិមនុស្សទាំងអស់ដែលកំពុងជាប់ពន្ធនាគារដោយមិនមានលក្ខខណ្ឌ ក្នុងពេលឆាប់ៗខាងមុខនេះ។

►► ធ្វើការស៊ើបអង្កេតដោយឯករាជ្យ ម៉ត់ចត់ និងឆាប់រហ័ស ទៅលើការគំរាមកំហែង និងការរំលោភបំពានផ្សេងៗ លើអ្នកការពារសិទ្ធិមនុស្ស និងធ្វើការចោទប្រកាន់លើជនល្មើសទាំងអស់ដោយត្រឹមត្រូវទៅតាមច្បាប់។

►► បញ្ឈប់ការបង្ក្រាបដោយមិនត្រឹមត្រូវមកលើប្រជាពលរដ្ឋដែលអនុវត្តសិទ្ធិសេរីភាពប្រមូលផ្តុំ និងបញ្ចេញមតិដោយអហិង្សា។ បញ្ឈប់ការប្រើប្រាស់កងកម្លាំងសន្តិសុខ ដើម្បីបង្ក្រាបលើការតវ៉ានិងបាតុកម្មអហិង្សានានា។

►► ពិនិត្យឡើងវិញនូវក្រមព្រហ្មទណ្ឌ ដើម្បីធានាថា ច្បាប់នេះស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងកាតព្វកិច្ចរបស់ខ្លួនតាមសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សដែលប្រទេសកម្ពុជាបានចុះហត្ថលេខាទទួលស្គាល់។ ជាពិសេសមាត្រាមួយចំនួនដែលមានលក្ខណៈស្រពិចស្រពិលនិងមានន័យទូលាយ ដូចជាបទល្មើសញុះញង់ ហើយនិងមាត្រាផ្សេងទៀតដែលប៉ះពាល់ដល់សេរីភាពសារព័ត៌មាននិងការបញ្ចេញមតិ ដូចជា ការបរិហាកេរ្តិ៍និងជេរប្រមាថ គួរត្រូវបានពិនិត្យឡើងវិញ ដើម្បីធានាថា មាត្រាទាំងនោះនឹងមិនរំលោភលើសេរីភាពសារព័ត៌មាននិងការបញ្ចេញមតិ និងមិនអនុញ្ញាតឲ្យមានការចាប់ខ្លួនដោយមិនត្រឹមត្រូវមកលើអ្នកការពារសិទ្ធិមនុស្សនោះទេ។

►► ពិនិត្យឡើងវិញនូវច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដើម្បីធានាថា មាត្រានៃច្បាប់នេះស្របតាមរដ្ឋធម្មនុញ្ញ ពាក់ព័ន្ធនឹងសេរីភាពក្នុងការប្រមូលផ្តុំ ជាពិសេសមាត្រាមួយចំនួនដែលទាមទារឲ្យមានការអនុញ្ញាតជាមុនពីអាជ្ញាធរ មុនពេលធ្វើការប្រមូលផ្តុំជាសាធារណៈនានា។ ផ្តល់ការណែនាំពន្យល់ឲ្យបានច្បាស់លាស់អំពីសេរីភាពនៃការជួបជុំ និងការបញ្ចេញមតិ។

►► អនុវត្តនូវអនុសាសន៍នានារបស់អ្នករាយការណ៍ពិសេស នៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដោយការពង្រឹងគោលការណ៍នីតិរដ្ឋនិងប្រព័ន្ធយុត្តិធម៌។ នេះ រួមទាំងការចាត់វិធានការធ្វើឲ្យប្រសើរឡើងនូវឯករាជ្យភាព និងអព្យាក្រឹតភាពនៃប្រព័ន្ធយុត្តាធិការ។ អំពាវនាវដល់មន្ត្រីតុលាការ សូមមេត្តាគោរពគោលការណ៍ឯករាជ្យរបស់តុលាការនៅគ្រប់សំណុំរឿង រួមទាំងសំណុំរឿងដែលពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស។

**យើងខ្ញុំក៏សង្ឃឹមថាសហគមន៍អន្តរជាតិ នឹងៈ**

►► បន្តអំពាវនាវ នៅក្នុងកិច្ចសន្ទនាទ្វេភាគីជាមួយអាជ្ញាធរកម្ពុជា រដ្ឋ និងស្ថាប័នអន្តរជាតិនានា សូមឲ្យអាជ្ញាធរកម្ពុជាបញ្ឈប់ការរំលោភបំពានលើក្រុមសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស។

►► អ្នកតំណាងប្រទេស និងពហុស្ថាប័ននានា គួរស្នើសុំចូលជួបសួរសុខទុក្ខអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ឃុំ និងចូលរួមសង្កេតការណ៍សវនាការនិងព្រឹត្តិការណ៍សំខាន់ផ្សេងៗ ដែលពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សនិងសកម្មជននយោបាយ។

►► បន្តធ្វើសហប្រតិបត្តិការ និងតាមដានជាមួយប្រទេសសមាជិកអង្គការសហប្រជាជាតិមួយចំនួនដែលបានលើកឡើងពីបញ្ហាសិទ្ធិមនុស្សកម្ពុជា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិកាលពីខែកញ្ញា ឆ្នាំ២០១៦ ដើម្បីជួយអន្តរាគមន៍ ប្រសិនបើអាជ្ញាធរកម្ពុជាមិនបញ្ឈប់ការរំលោភសិទ្ធិមនុស្សនិងសង្គមស៊ីវិល និងដោះលែងអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ឃុំនោះទេ។

ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥
ករណីទី១

### សមាជិកសហជីពទទួលការគំរាមកំហែង[១]
រាជធានីភ្នំពេញ

ការគម្រាមកំហែង/ច្បាប់

- សមាជិកសហជីពចំនួន បីនាក់ត្រូវបានកោះហៅដើម្បីសាកសួរដោយចៅក្រមស៊ើបសួររាជធានីភ្នំពេញ បន្ទាប់ពីរោងចក្រ ជីន វីន បានដាក់ពាក្យបណ្ដឹងចោទប្រកាន់ពួកគេទាំងបីនាក់ពីបទញុះញង់ឲ្យកម្មកររោងចក្រកាត់ដេរធ្វើការតវ៉ាខុសច្បាប់ ។

ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០១៥
ករណីទី២
(សូមមើលករណីទី២៦)

### សមាជិកសហជីពត្រូវបានឃាត់ខ្លួន[២]
ក្រុងបាវិត ខេត្តស្វាយរៀង

ការរំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន

- សមាជិកប្រាំមួយនាក់ នៃសម្ព័ន្ធសហជីពចលនាកម្មករត្រូវបានចាប់ខ្លួនដោយនគរបាលនៃអធិការដ្ឋាននគរបាលក្រុងបាវិត ដែលដឹកនាំដោយ លោក កែវ គង់ នៅពេលដែលពួកគេចែកខិតប័ណ្ណគាំទ្រប្រធានសហជីពលោក ប៉ាវ ស៊ីណា នៅតំបន់សេដ្ឋកិច្ចពិសេស។ អ្នកទាំងនោះត្រូវបានដោះលែងវិញ បន្ទាប់ពីបានចុះហត្ថលេខាដោយសន្យាថានឹងឈប់ចែកចាយខិតប័ណ្ណឲ្យទៅកម្មករទៀត ប្រសិនបើគ្មានការអនុញ្ញាត។

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥
ករណីទី ៣

### តំណាងសហគមន៍ត្រូវបានកោះហៅ[៣]
សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

ការគំរាមកំហែង - ផ្លូវច្បាប់

- សកម្មជនដីធ្លីពីររូបគឺ អ្នកស្រី ហង្ស ចិន្តា និងអ្នកស្រី ហង្ស សុភាព ដែលជាតំណាងប្រជាពលរដ្ឋ២៤គ្រួសារ ជាប់ពាក់ព័ន្ធនឹងករណីជម្លោះមួយតាំងពីឆ្នាំ១៩៩៦ ត្រូវបានព្រះរាជអាជ្ញាខេត្តព្រះសីហនុកោះហៅទៅឆ្លើយបំភ្លឺ ខណៈដែលអ្នកទាំងនោះកំពុងបន្តយុទ្ធនាការអហិង្សាដើម្បីទាមទារដីធ្លីមកវិញ។ អ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទប៉ះពាល់កម្មសិទ្ធិឯកជន យោងតាមមាត្រា២៤៨ និងមាត្រា២៥៣នៃច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥
ករណីទី៤
(សូមមើលករណីទី ៥ ៦ ១១ ១៣ ១៧)

### សកម្មជនការពារបរិស្ថានត្រូវបាននិរទេស[៤]
រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- សកម្មជនការពារបរិស្ថាន និងស្ថាបនិកអង្គការមាតាធម្មជាតិ លោក អាឡិចហ្សង់ដ្រូ ហ្គន់ហ្សាឡេហ្ស ដេវិតសិន សញ្ជាតិអេស្ប៉ាញ ត្រូវបានចាប់ខ្លួន និងបញ្ជូនចេញពីប្រទេសដោយអគ្គនាយកដ្ឋាននគរបាលអន្តោប្រវេសន៍ដែលដឹកនាំដោយអគ្គនាយករង លោក នៅ លក្ខណា នៅពេលដែលលោកបានស្នាក់នៅប្រទេសកម្ពុជាលើសចំនួនថ្ងៃកំណត់ បន្ទាប់ពីអាជ្ញាធរកម្ពុជាបដិសេធការបន្តទិដ្ឋាការរបស់លោក ដោយសារតែភាពសកម្មជននិយមរបស់លោកប្រឆាំងនឹងគម្រោងសាងសង់ទំនប់វារីអគ្គិសនី ដែលមានផលប៉ះពាល់ខ្លាំងនៅក្នុងតំបន់អារ៉ែង។

[១] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ PP016THI15

[២] ប៊ែន សុខប៉ាន "សមាជិកសហជីពប្រាំមួយនាក់ដែលត្រូវបានចាប់ខ្លួនពីបទញុះញង់ ត្រូវបានដោះលែងនៅក្រុងបាវិត" កាសែតខេមបូឌា ដេលី ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ https://www.cambodiadaily.com/news/six-unionists-arrested-released-in-bavet-city-over-incitement-77403/

[៣] ម៉របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ SV009LG15

[៤] សេចក្ដីថ្លែងការណ៍រួម "ក្រុមសង្គមស៊ីវិលសោកស្ដាយការមិនបន្តទិដ្ឋាការដល់សកម្មជនដ៏ល្បីឈ្មោះម្នាក់" ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥, http://www.licadho-cambodia.org/pressrelease.php?perm=373

ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥
**ករណីទី៥**
(សូមមើលករណីទី ៤ ៦ ១១ ១៣ ១៧)

### បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលត្រូវបានរារាំងមិនឱ្យប្រាប់ អ្នកភូមិអំពីការបូមខ្សាច់[៥]
### ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង

ការរំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ

- បុគ្គលិកអង្គការមាតាធម្មជាតិលោក សាន់ ម៉ាឡា ត្រូវបានរារាំងមិនឱ្យប្រាប់អ្នកភូមិកោះស្រឡៅ អំពី ផលប៉ះពាល់អវិជ្ជមាននៃការបូមខ្សាច់ និងហាមមិនឲ្យធ្វើសកម្មភាពរារាំងដល់ការបូមខ្សាច់ ដោយប្រធានក្រុមប្រឹក្សាឃុំជ្រោយប្រស់។

ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥
**ករណីទី៦**
(សូមមើលករណីទី ៤ ៥ ១១ ១៣ ១៧)

### សកម្មជនការពារបរិស្ថានត្រូវបានឃាត់ខ្លួន[៦]
### សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ការរំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន

- សកម្មជនការពារបរិស្ថាននៃអង្គការមាតាធម្មជាតិចំនួនបីរូបរួមមានលោក ចេក នេត្រា លោកខឹម គុណឌី លោក សន ចាន់ដារ៉ា ព្រមទាំងមន្ត្រីផ្នែកប្រព័ន្ធផ្សព្វផ្សាយនៃសមាគមអាដហុក លោក ឌិត សុជី ត្រូវបានឃាត់ខ្លួនដោយខុសច្បាប់ដោយកងកម្លាំងចម្រុះនៃសន្តិសុខ និងនគរបាលខណ្ឌចំការមនចំនួន ១០នាក់ ខណៈដែលជនរងគ្រោះបានប្រមូលផ្តុំគ្នានៅមុខរដ្ឋសភាដើម្បីធ្វើការតវ៉ា ជំទាស់នឹងការបូមខ្សាច់នៅក្នុងខេត្តកោះកុង។ ពួកគេទាំងបួនរូបនេះត្រូវបានដោះលែងនៅព្រឹកថ្ងៃដដែល បន្ទាប់ពីបុគ្គលិករបស់អង្គការមាតាធម្មជាតិទាំងបីនាក់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិនធ្វើការតវ៉ាទៀត ។

ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៥
**ករណីទី៧**

### តំណាងសហគមន៍ត្រូវបានឃាត់ខ្លួន[៧]
### ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

ការគំរាមកំហែង - ផ្លូវច្បាប់

- តំណាងសហគមន៍លោក សៀន វី ត្រូវបានឃាត់ខ្លួននៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យរយៈពេលពីរថ្ងៃដោយកងរាជអាវុធហត្ថនិងអាជ្ញាធរមូលដ្ឋានបន្ទាប់ពីលោកបានដឹកនាំប្រជា-ពលរដ្ឋចំនួន ២០គ្រួសារ ដើម្បីធ្វើការតវ៉ាពាក់ព័ន្ធនឹងជម្លោះដីធ្លីមួយ ។ នៅថ្ងៃទី០៧ ខែកក្កដា លោកត្រូវបានចោទប្រកាន់ពីបទ"ប៉ះពាល់កម្មសិទ្ធិឯកជន" តាមមាត្រា២៤៨ និងមាត្រា២៥៣ នៃច្បាប់ភូមិបាល ប៉ុន្តែក្រោយមកត្រូវបានដោះលែងឲ្យនៅក្រៅឃុំវិញ។ ករណីបណ្តឹងលើរូបលោកនេះនៅមិនទាន់ដោះស្រាយនៅឡើយទេ ។

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥
**ករណីទី៨**

(សូមមើលករណីទី៩ ១០)

### សកម្មជនជំទាស់នឹងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានឃាត់ខ្លួន[៨]
### សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- ពលរដ្ឋចំនួនប្រាំមួយនាក់ត្រូវបានចាប់ខ្លួនពីសំណាក់កងសន្តិសុខ និងនគរបាល ដែលដឹកនាំដោយអភិបាលរងរាជធានីភ្នំពេញឯកឧត្តម ឃួន ស្រេង និងស្នងការរងនគរបាលរាជធានីភ្នំពេញ លោក អ៊ុច សុខុន បន្ទាប់ពីធ្វើការតវ៉ាជំទាស់នឹងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅមុខរដ្ឋសភា។

[៥] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KK011OFEA15

[៦] សេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សកម្មជនអង្គការមាតាធម្មជាតិត្រូវបានចាប់ខ្លួនក្នុងទីក្រុងភ្នំពេញ ខណៈ ដែលប៉ុនប៉ងធ្វើការតវ៉ាប្រឆាំងនឹងសកម្មភាពបូមខ្សាច់ក្នុងខេត្តកោះកុង" ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=61&id=5

[៧] ឆាយ ចំន្ទនីដា "បុរសម្នាក់ដែលចាប់ខ្លួនក្នុងរឿងជម្លោះដីធ្លីត្រូវបានដោះលែងវិញ" កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥, http://www.phnompenhpost.com/national/land-disputant-freed-bail-b-meanchey

[៨] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ PP071IAD15

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥
**ករណីទី៩**
(សូមមើលករណីទី ៨ ១០)

## សកម្មជនដីធ្លីត្រូវបានឃាត់ខ្លួន[៩]

សង្កាត់អូរឫស្សី ២ ខណ្ឌ៧មករា រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំគ្នា - ហិង្សា និងការចាប់ខ្លួន

- តំណាងសហគមន៍ចំនួនប្រាំនាក់ រួមមានអ្នកស្រីទេព វន្នី អ្នកស្រី ឆាយ គឹមហ៊ន អ្នកស្រី ប៊ូវ សោភា អ្នកស្រី គង់ ចន្ថា និងអ្នកស្រីសុង ស្រីលាភ ត្រូវបានឃាត់ខ្លួននៅប៉ុស្តិ៍នគរបាលសង្កាត់អូរឫស្សី២ និងអធិការដ្ឋាននគរបាលខណ្ឌ៧មករា ដែលដឹកនាំដោយអភិបាលខណ្ឌ៧មករា បន្ទាប់ពីពួកគេចែកខិតប័ណ្ណជំទាស់នឹងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងប៉ុនប៉ងធ្វើការដើរក្បួននៅជុំវិញផ្សារជាមួយនឹងអ្នកចូលរួមប្រមាណ ៥០នាក់ទៀត។ ពួកគេត្រូវបានដោះលែងវិញ បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងថានឹងបញ្ឈប់សកម្មភាពរបស់ពួកគេ ។

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥
**ករណីទី១០**
(សូមមើលករណីទី ៨ ៩)

## អ្នកតវ៉ាជំទាស់ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានចាប់ខ្លួនបន្ថែមទៀត

រាជធានីភ្នំពេញ[១០]

ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- យុវជនប្រាំនាក់ និងយុវតីម្នាក់មកពីក្រុមយុវជននៅខេត្តព្រះវិហារ និងរាជធានីភ្នំពេញ ត្រូវបានចាប់ខ្លួន បន្ទាប់ពីអ្នកទាំងនោះបានប្រមូលផ្តុំគ្នាដើម្បីតវ៉ាជំទាស់នឹងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅមុខរដ្ឋសភា ។ យុវជនប្រាំមួយនាក់នេះដែលរួមមាន ជុំ ហួរ និងជុំ ហួត មកពីក្រុមយុវជនខ្មែរមហានគរ រឿន រតនា មួង សូនី និងសួន វាសនា មកពីសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ និងមាស លក្ខិណា មកពីចលនាស្ត្រីគណបក្សសង្គ្រោះជាតិខណ្ឌជ្រោយចង្វារ ត្រូវបានឃាត់ខ្លួនអស់រយៈពេលជាច្រើនម៉ោងនៅសាលាខណ្ឌចំការមន ក្នុងរាជធានីភ្នំពេញ។

ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥
**ករណីទី១១**
(សូមមើលករណីទី ៤ ៥ ៦ ១៣ ១៧)

## សកម្មជនការពារបរិស្ថានត្រូវបានចាប់ខ្លួន[១១]

ឃុំកណ្តាល ស្រុកបូទុមសាគរ ខេត្តកោះកុង

ការគំរាមកំហែង - ផ្លូវច្បាប់

- សកម្មជនបីនាក់មកពីអង្គការមាតាធម្មជាតិរួមមាន ទ្រី សុវិគា អាយុ ២៣ឆ្នាំ សាន់ ម៉ាឡា អាយុ ២៣ឆ្នាំ និងស៊ឹម សំណាង អាយុ ២៨ឆ្នាំ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៧ ខែសីហា អំឡុងពេលពួកគេធ្វើយុទ្ធនាការតវ៉ាឱ្យបញ្ឈប់ការបូមខ្សាច់ដែលគេអះអាងថាធ្វើឡើងដោយខុសច្បាប់ ក្នុងខេត្តកោះកុង។ ពួកគេត្រូវបានចោទប្រកាន់យោងតាមមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌពីបទគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបទបញ្ជាអ្វីមួយ និងត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តកោះកុង ។

ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥
**ករណីទី១២**

## និស្សិតម្នាក់ត្រូវបានចាប់ខ្លួនដោយសារការសរសេរលើបណ្តាញសង្គមហ្វេសប៊ុក[១២]

សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- និស្សិតសាកលវិទ្យាល័យខេមរៈនិងជាប្រធានបណ្តាញនិស្សិតកម្ពុជា គង់ រ៉ៃយ៉ា អាយុ ២៥ឆ្នាំ ត្រូវបានចាប់ខ្លួនដោយនគរបាលប្រមាណជា ១០នាក់ ដែលមកពីនាយកដ្ឋានសន្តិសុខនៃក្រសួងមហាផ្ទៃ បន្ទាប់ពីរូបខ្លួនបានអំពាវនាវតាមបណ្តាញសង្គមហ្វេសប៊ុករបស់ខ្លួនឱ្យមានការធ្វើបដិវត្តន៍ពណ៌នៅកម្ពុជា ។

[៩] អត្ថបទខ្លីរបស់អង្គការលីកាដូ "សកម្មជនប្រាំនាក់ត្រូវបានឃាត់ខ្លួនបន្ទាប់ពីបានចែកខិតប័ណ្ណជំទាស់នឹងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល" ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥, http://www.licadho-cambodia.org/flashnews.php?perm=132

[១០] អត្ថបទខ្លីរបស់អង្គការលីកាដូ "មនុស្សប្រាំមួយនាក់ត្រូវបានចាប់ខ្លួននៅមុខវិមានរដ្ឋសភាជាតិពេលតវ៉ាជំទាស់ច្បាប់សមាគម និងអង្គការ" ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥, http://www.licadho-cambodia.org/flashnews.php?perm=136

[១១] អត្ថបទខ្លីរបស់អង្គការលីកាដូ "អ្នកគាំទ្រសកម្មជនអង្គការមាតាធម្មជាតិបីនាក់ត្រូវបានគេ រារាំងពីការចូលក្នុងក្រុងខេមរភូមិន្ទខេត្តកោះកុង" ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥, http://www.licadho-cambodia.org/flashnews.php?perm=142

[១២] ប៊ិច សុធារី "និស្សិតម្នាក់ត្រូវចាប់ឃុំ បន្ទាប់ពីប្រកាសធ្វើបដិវត្តន៍ពណ៌" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥១៣ ឃុត សុភ៌ក្រ្តចរិយា, "ស្រ្តី និងនគរបាលប៉ះទង្គិចគ្នាពាក់ព័ន្ធនឹងការតវ៉ារឿងដីធ្លី", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/women-cops-clash-land-protest

**ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥**
**ករណីទី១៣**
**(សូមមើលករណីទី ៤ ៥ ៦ ១១ ១៧)**

### អ្នកតវ៉ានិងអ្នកឃ្លាំមើលសិទ្ធិមនុស្សត្រូវបានឃាត់ខ្លួន[១៣]
### ឃុំកណ្ដាល ស្រុកបូទុមសាគរ ខេត្តកោះកុង

ការបំពានលើសេរីភាពក្នុងការជួបជុំគ្នា - ហិង្សា និងការចាប់ខ្លួន

- អ្នកតវ៉ា និងសកម្មជនចំនួន ១៧នាក់ ដែលរួមមានអ្នកឃ្លាំមើលសិទ្ធិមនុស្សអង្គការលីកាដូ និងសមាគមអាដហុកចំនួនប្រាំនាក់ បុគ្គលិកពេទ្យម្នាក់ និងអ្នកសារព័ត៌មានចំនួនពីរនាក់ត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅកាន់ស្នងការនគរបាលខេត្តកោះកុងដោយក្រុមនគរបាលនិងកងរាជអាវុធហត្ថចំនួន ៦០នាក់ ដែលដឹកនាំដោយស្នងការរងនគរបាលខេត្តកោះកុង លោក គង់ យ៉ាន នៅពេលដែលអ្នកភូមិ និងសកម្មជនចំនួន ៩០នាក់ ធ្វើការតវ៉ាដោយសន្តិវិធីទាមទារឱ្យដោះលែងសកម្មជនអង្គការមាតាធម្មជាតិ បីនាក់ដែលកំពុងជាប់ពន្ធនាគារ និងអំពាវនាវឲ្យមានដំណោះស្រាយទៅលើទំនាស់ដីធ្លីរបស់សហគមន៍។ អ្នកតវ៉ា និងសកម្មជនទាំងនេះត្រូវបានដោះលែងវិញបន្ទាប់ពីការឃាត់ខ្លួនអស់រយៈពេលប្រាំបីម៉ោង។

**ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥**
**ករណីទី១៤**

### សកម្មជនដែលរងរបួសអំឡុងពេលតវ៉ារឿងដីធ្លីត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេលពីរឆ្នាំ[១៤]
### រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- សកម្មជន អ៊ុក ពេជ្រសំណាង ត្រូវបានផ្ដន្ទាទោសឲ្យជាប់ទោសពីបទប្រើប្រាស់អំពើហិង្សាដោយចេតនា និងរារាំងសមត្ថកិច្ច ទោះបីជាមានសក្ខីកម្មផ្ទុយ និងកង្វះខាតភស្តុតាងក៏ដោយ និងត្រូវបានដាក់ឱ្យជាប់ពន្ធនាគារចំនួន ពីរឆ្នាំបន្ថែមពីលើទោសជាប់ពន្ធនាគារ៧ឆ្នាំនៃការផ្ដន្ទាទោសពីមុនដែលលោកកំពុងអនុវត្តទោស។

**ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥**
**ករណីទី១៥**

### អ្នកដឹកនាំសហគមន៍ត្រូវបានជំនុំជម្រះពីបទឈូសឆាយដីព្រៃ របស់រដ្ឋ[១៥]
### ខេត្តស្វាយរៀង

ការគំរាមកំហែង - ផ្លូវច្បាប់

- បុរសពីរនាក់មកពីសហគមន៍អណ្ដូងត្របែក ត្រូវបានជំនុំជម្រះក្ដីដោយតុលាការខេត្តស្វាយរៀងពីបទឈូសឆាយដីព្រៃរបស់រដ្ឋ ។ លោក សួន សីហា និងលោក សួន ហុងលី ត្រូវបាន ចោទប្រកាន់ យោងតាមមាត្រា ៩៧ នៃច្បាប់ស្ដីពីព្រៃឈើឆ្នាំ ២០១២ ដែលការចោទប្រកាន់ នេះគឺជាវិធីសាស្ត្រគំរាមកំហែងដល់សហគមន៍អណ្ដូងត្របែក ដែលតែងតែតវ៉ាពីការរំលោភបំពានដីធ្លីជាច្រើនដោយអាជ្ញាធរមូលដ្ឋានដែលគេបានអះអាងថារួមមានទាំងមន្ត្រីរដ្ឋបាលព្រៃឈើផងដែរ ចាប់តាំងពីឆ្នាំ ២០០៨ មក។

**ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥**
**ករណីទី១៦**

### សកម្មជនការពារបរិស្ថានត្រូវបានចាប់និងឃាត់ខ្លួន[១៦]
### ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង

ការគំរាមកំហែង - ផ្លូវច្បាប់

- តំណាងសហគមន៍តំបន់អារ៉ែងនិងជាក្រុមប្រឹក្សាឃុំមកពីគណបក្សប្រជាជនកម្ពុជា លោក វ៉ែន វន ត្រូវបានចាប់ខ្លួនពីបទល្មើសពាក់ព័ន្ធនឹងភាពសកម្មនិយមរបស់លោក និងត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តកោះកុង។ លោកគឺជាអ្នកសកម្មជាងគេនៅក្នុងយុទ្ធនាការអហិង្សារបស់សហគមន៍តំបន់អារ៉ែង ដើម្បីបញ្ឈប់ការកសាងទំនប់វារីអគ្គិសនីជំទាប់ស្ទឹងជម្រៅរបស់ក្រុមហ៊ុនភាពីម៉ិច ដែលជាក្រុមហ៊ុនរបស់សមាជិកព្រឹទ្ធសភាគណបក្សកាន់អំណាច លោក ឡៅ ម៉េងឃីន និងក្រុមហ៊ុនចិន ស៊ីណូហាយដ្រូ ជាដៃគូ។ លោកត្រូវបានចោទប្រកាន់ និងផ្ដន្ទាទោសយោងតាមមាត្រា ៩៨ នៃច្បាប់ស្ដីពីព្រៃឈើ និងមាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌដោយសារលោកបានដឹកនាំការសាងសង់កន្លែងប្រជុំតូចមួយនៅក្នុងឃុំ ដែលជាកន្លែងសាងសង់ដោយសហគមន៍តំបន់អារ៉ែងសម្រាប់ជួយដល់សកម្មភាពរបស់ពួកគេ។
- 

[១៣] សេចក្ដីថ្លែងការណ៍រួម "សមាគមអាដហុក អង្គការលីកាដូ និងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ សូមអំពាវនាវឱ្យមានការដោះលែងសកម្មជន និងអ្នកឃ្លាំមើលទាំង ១៧នាក់ ជាបន្ទាន់" ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥, http://www.licadho-cambodia.org/pressrelease.php?perm=391

[១៤] អត្ថបទខ្លីរបស់អង្គការលីកាដូ "សកម្មជនដែលរងរបួសអំឡុងពេលតវ៉ារឿងដីធ្លីត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេល ពីរឆ្នាំ" ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥, http://www.licadho-cambodia.org/flashnews.php?perm=143

[១៥] អត្ថបទខ្លីរបស់អង្គការលីកាដូ "អ្នកដឹកនាំសហគមន៍ត្រូវបានជំនុំជម្រះពីបទឈូសឆាយដីព្រៃរបស់រដ្ឋ" ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, http://www.licadho-cambodia.org/flashnews.php?perm=144

[១៦] អត្ថបទខ្លីរបស់អង្គការលីកាដូ "អ្នកតំណាងសហគមន៍តំបន់អារ៉ែងត្រូវបានចាប់ និងឃុំខ្លួន ក្នុងពន្ធនាគារ" ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥, http://www.licadho-cambodia.org/flashnews.php?perm=147

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៥
ករណីទី១៧
(សូមមើលករណីទី ១៣ ២០ ២៨ ៤៦)

**និស្សិត និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលត្រូវបានគំរាមកំហែងដោយកាំភ្លើង[១៧]**
យុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង
ការគំរាមកំហែង - ហិង្សា

- និស្សិតសាកលវិទ្យាល័យ និងបុគ្គលិកអង្គការមាតាធម្មជាតិចំនួន ប្រាំពីរនាក់ ត្រូវបានរារាំង ពីការរៀបចំសិក្ខាសាលាស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដោយមន្ត្រីនគរបាលឃុំអណ្តូងទឹកចំនួន បីនាក់ ដែលមានប្រដាប់ដោយកាំភ្លើង ។ ការរារាំងនេះត្រូវបានដឹកនាំដោយនាយនគរបាល និងមេឃុំអណ្តូងទឹក។

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥
ករណីទី១៨

**អ្នកតំណាងដីធ្លីត្រូវបានឃាត់ខ្លួន[១៨]**
ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ
ការបំពានលើសេរីភាពក្នុងការជួបជុំគ្នា - ហិង្សា និងការចាប់ខ្លួន

- ខណៈដែលគ្រួសារចំនួន ២១ ពាក់ព័ន្ធនឹងទំនាស់ដីធ្លីបានធ្វើការតវ៉ាជំទាស់នឹងការឈូសឆាយដីរបស់ពួកគេ តំណាងសហគមន៍ ពីររូបត្រូវបានឃាត់ខ្លួនអស់រយៈពេលជាច្រើនម៉ោងដោយក្រុមនគរបាល និងទាហានចំនួន ១០នាក់ ដែលដឹកនាំដោយ នាយសង្កាត់រដ្ឋបាលព្រៃឈើ សន្ទុក លោក ទឹប ញ៉ើតា ដែលបានចាប់បង្ខំឱ្យជនរងគ្រោះទាំងពីរនាក់ផ្តិតមេដៃសន្យានឹងបញ្ឈប់ការដាក់បណ្តឹងរឿងការឈូសឆាយដី។

ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥
ករណីទី១៩

**អ្នកតំណាងសហគមន៍នៅខេត្តរតនគិរីត្រូវបានដាក់ពន្ធនាគារបន្ទាប់ពីមានការផ្តន្ទាទោសដោយមិនយុត្តិធម៌[១៩]**
ខេត្តរតនគិរី
ការគំរាមកំហែង - ផ្លូវច្បាប់

- តំណាងសហគមន៍ចំនួន បីនាក់ត្រូវបានតុលាការខេត្តរតនគិរីផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួនពីរឆ្នាំ។ លោក សួត សឿន លោក អែម ចាន់ និងលោក ជ្រឹក ទូក ត្រូវបានផ្តន្ទាទោសឲ្យជាប់ទោសពីបទរំលោភកាន់កាប់អចលនវត្ថុអ្នកដទៃ យោងតាមមាត្រា ២៤៧ ២៤៨ និង២៥៣ នៃច្បាប់ភូមិបាល ។ ទោះបីជាមានការខ្វះខាតភស្តុតាង ក៏ដោយ អ្នកទាំងបីរូបនេះត្រូវបានដាក់ទោសឲ្យជាប់ពន្ធនាគារកម្រិតអតិបរមា និងត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារខេត្តរតនគិរីភ្លាមៗបន្ទាប់ពីត្រូវបានផ្តន្ទាទោសរួច។

ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៥
ករណីទី២០
(សូមមើលករណីទី ១៧ ២០ ២៨ ៤៦)

**សកម្មជនការពារបរិស្ថានត្រូវបានឃាត់ខ្លួន[២០]**
ឃុំតាតៃក្រោម ស្រុកកោះកុង ខេត្តកោះកុង
ការរំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ

- សកម្មជនការពារបរិស្ថានពីរនាក់មកពីអង្គការមាតាធម្មជាតិ អ្នកភូមិបួននាក់និងអ្នកសារព័ត៌មានជនជាតិបរទេសម្នាក់ ត្រូវបានឃុំខ្លួនដោយខុសច្បាប់នៅក្នុងផ្ទះឯកជនមួយកន្លែងអស់រយៈពេលជាច្រើនម៉ោង ដោយបុគ្គលិកក្រុមហ៊ុន ឧត្តម សីម៉ា បន្ទាប់ពីអ្នកទាំងនោះព្យាយាមថតយករូបភាពនិងវីដេអូពីសកម្មភាពបូមខ្សាច់របស់ក្រុមហ៊ុន។ បុគ្គលិកក្រុមហ៊ុននោះក៏បានលុបចោលរូបភាពនិងវីដេអូទាំងនោះផងដែរ។

[១៧] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KK018OFEA15
[១៨] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KT048LG15
[១៩] អត្ថបទខ្លីរបស់អង្គការលីកាដូ "អ្នកតំណាងសហគមន៍នៅខេត្តរតនគិរីត្រូវបានដាក់ពន្ធនាគារបន្ទាប់ពីមានការផ្តន្ទាទោសដោយមិនយុត្តិធម៌" ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥, http://www.licadho-cambodia.org/flashnews.php?perm=151
[២០] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KK021IAD15




ការប្រមូលផ្តុំមួយដែលត្រូវបានធ្វើឡើង ដើម្បីរំលឹកខួបពីរឆ្នាំនៃការបង្ក្រាបទៅលើ
ក្រុមបាតុករ ជាច្រើននៅលើផ្លូវវេងស្រេង កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៦

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥
**ករណីទី២១**

### អ្នកតំណាងសហគមន៍ត្រូវបានចាប់ និងឃាត់ខ្លួន[២១]

សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

ការគំរាមកំហែង - ផ្លូវច្បាប់

- លោក ឈេង ប៊ុនហាក់ ដែលជាអ្នកតំណាងឲ្យគ្រួសារចំនួន ៥០ដែលប្រឈមនឹងការបាត់បង់ដីលំនៅដ្ឋានដោយសារការសាងសង់ផ្លូវរថភ្លើង ត្រូវបានចាប់ខ្លួនដោយក្រុមនគរបាល បន្ទាប់ពីលោកបានដឹកនាំការដើរក្បួនអហិង្សានៅក្នុងក្រុងប៉ោយប៉ែតដើម្បីទាមទារឲ្យមានការផ្ដល់សំណង និងការតាំងទីលំនៅថ្មី។លោកត្រូវបានឃុំខ្លួនអស់រយៈពេលចំនួនបីថ្ងៃមុនពេលត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍ យោងតាមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងពីបទបង្កជាឧបសគ្គដល់ចរាចរណ៍ យោងតាមមាត្រា ៨០ នៃច្បាប់ស្ដីពីចរាចរណ៍កម្ពុជា។ បុគ្គលិកអង្គការលីកាដូ និងសមាគមអាដហុក ក៏ត្រូវបានកោះហៅដើម្បីសាកសួរពាក់ព័ន្ធនឹងករណីនេះផងដែរ ។

ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៦
**ករណីទី២២**

### ការវាយបំបែកការប្រមូលផ្ដុំគ្នាដោយកម្លាំង[២២]

រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំគ្នា - ហិង្សា និងការចាប់ខ្លួន

- សមាជិកសហជីព កម្មករកាត់ដេរ ព្រះសង្ឃ និងសកម្មជនសិទ្ធិមនុស្សប្រមាណ ៣០០នាក់ បានប្រមូលផ្ដុំគ្នាដើម្បីរំលឹកខួបលើកទីពីរនៃការបង្ក្រាបលើ ការតវ៉ារបស់កម្មករកាត់ដេរដែលបានបណ្ដាលឲ្យមានការស្លាប់នៅផ្លូវ វេង ស្រេង។ ក្រុមអ្នកទាំងនោះត្រូវបានកម្លាំងនគរបាលបង្ក្រាបកុបកម្ម កងរាជអាវុធហត្ថ និងសន្តិសុខចំនួន ៥០០នាក់ដែលប្រដាប់ដោយដំបង និងខែលបិទផ្លូវរារាំង និងវាយបំបែក។ ស្ថិតក្នុងក្រុមនោះក៏មានប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ លោក វន់ ពៅ ផងដែរ ដែលលោកត្រូវបាននាយករដ្ឋមន្ត្រីធ្វើការព្រមាននៅថ្ងៃបន្ទាប់ចំពោះការចូលរួមរបស់លោក។

ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦
**ករណីទី២៣**

### កម្មករកាត់ដេរនិងសមាជិកសហជីពប្រាំបីនាក់ត្រូវបានរំលោភបំពាន[២៣]

ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល

ការបំពានលើសេរីភាពក្នុងការជួបជុំគ្នា - ហិង្សា និងការចាប់ខ្លួន

- កម្មកររោងចក្រកាត់ដេរ និងសមាជិកសហជីពប្រាំបីនាក់ត្រូវបានវាយប្រហារដោយបំពង់ដែកដំបង និងកាំបិតដោយបុគ្គលិកនិងសន្តិសុខចំនួន ៤០នាក់ដែលត្រូវបានជួលដោយរោងចក្រស្តារឡៃថ៍ អឹភែរិល (Starlight Apparel)។ការវាយប្រហារនេះបានកើតឡើងនៅពេលដែលកម្មកររោងចក្រ ស្តារឡៃថ៍ អឹភែរិល និងសមាជិកសហជីពចំនួន ប្រមាណ ៦០០នាក់បានប្រមូលផ្ដុំគ្នាតវ៉ាទាមទារឲ្យមានលក្ខខណ្ឌការងារល្អជាងមុន។

[២១] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ BM068IAD15 និង ចេង សុខង "អ្នករៀបចំការតវ៉ាដែលមានរូបទីងមោងត្រូវបានចោទប្រកាន់ពីបទញុះញង់", កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥

[២២] ម៉ិច ដារ៉ា "អាជ្ញាធរបំបែកការប្រមូលផ្តុំរំឭកខួបការបាញ់សម្លាប់កម្មករនៅផ្លូវវេងស្រេង" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និង Frontline Defenders, "ករណី៖ វន់ ពៅ" ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦d

[២៣] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ PP014PA16

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦
**ករណីទី២៤**
(សូមមើលករណីទី ២៥ )

### អ្នកតវ៉ាត្រូវបានវាយដំដោយជនពាល និងចាប់ខ្លួន[២៤]

សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន ជម្លោះរវាងនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារដោយសារពួកគេបាននាំគ្នាបង្កើតជា សហជីព និងក្រុមហ៊ុនកាពីតូល ជានិយោជក បានឈានដល់អំពើហិង្សានៅពេលដែលការតវ៉ាដោយសន្តិវិធីនៅ មុខក្រុមហ៊ុនត្រូវបានវាយបំបែកយ៉ាងឃោរឃៅ ដោយសមាជិកសមាគមរួបរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជាដែលត្រូវបានរៀបចំឡើងដោយអាជ្ញាធរ (CCDA)។ សមាជិកសមាគមរួបរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជាបានកាន់ដំបងដែក និងញញួរ វាយដំនិងបង្ករបួសយ៉ាងធ្ងន់ធ្ងរដល់អ្នកតវ៉ាមួយចំនួន។ មិនមានសមាជិកសមាគមរួបរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជាណាម្នាក់ត្រូវបានចាប់ខ្លួនឡើយបន្ទាប់ពីមានការវាយប្រហារនេះ ប៉ុន្តែអ្នកតវ៉ាពីរនាក់ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ និងត្រូវបានជាប់ពន្ធនាគារអស់រយៈពេលជិតពីរខែ មុនពេលអ្នកទាំងពីរត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។

ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦
**ករណីទី២៥**
(សូមមើលករណីទី ២៤)

### អ្នកដឹកនាំសហជីពត្រូវបានផ្តន្ទាទោស[២៥]

រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- ក្រោយពីការតវ៉ាចំពោះក្រុមហ៊ុនកាពីតូលពីរថ្ងៃ អ្នកដឹកនាំសហជីពលេចធ្លាបួនរូប រួមមាន ប្រធានសហភាពការងារកម្ពុជា (CLC) លោក អាត់ ធន់ និងអគ្គលេខាធិការ CLC លោក គង់ អាទិត្យ ប្រធានសមាគមកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា លោក សុខ ឈុនអឿង និងលេខាធិការសហព័ន្ធកម្មករដឹកជញ្ជូនកម្ពុជា លោក អឿន គឹមហុង ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការតវ៉ានេះពីបទប្រើហិង្សាដោយចេតនា ប្រឆាំងនឹងមន្ត្រីរាជការនិងបទបង្កជាឧបសគ្គដល់ចរាចរណ៍ ក្នុងចំនោមអ្នកទាំងបួននេះមានតែម្នាក់ប៉ុណ្ណោះនៅកន្លែងដែលអំពើហិង្សាកើតឡើង ហើយអ្នកទាំងបួននេះមិនបានចូលរួមពាក់ព័ន្ធនឹងអំពើហិង្សាឡើយ។

ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦
**ករណីទី២៦**

### សមាជិកសហជីពត្រូវបានចាប់ឃាត់ខ្លួន និងវាយដំឲ្យសារភាព[២៦]

សង្កាត់ការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

ការរំលោភបំពានពីអាជ្ញាធរ - ការចាប់ និងឃាត់ខ្លួន

- សមាជិកសហជីពម្នាក់ត្រូវបានចាប់ និងឃាត់ខ្លួនបន្ទាប់ពីត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ក្រោយពីមានការធ្វើបាតុកម្មដោយកម្មកររោងចក្រ អ៊ែចាយល៍ ស្វេតធ៍ (Agile Sweater) ដែលទាមទារឲ្យមានការដោះលែងសមាជិកសម្ព័ន្ធសហជីពចលនាកម្មករចំនួន ប្រាំនាក់។ លោកត្រូវបានចាប់ខ្លួនខណៈដែលលោកកំពុងបើកបរកាត់ផ្សារខេត្ត កំពង់ស្ពឺ និងត្រូវបានវាយដំបង្ខំឲ្យផ្តល់ចម្លើយសារភាពដោយនគរបាល។

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦
**ករណីទី២៧**

### សកម្មជនក្នុងសហគមន៍ត្រូវបានគំរាមកំហែង[២៧]

ខេត្តកំពង់ចាម

ការរំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ

- អ្នកតំណាងសហគមន៍ម្នាក់ត្រូវបានមន្ត្រីកងរាជអាវុធហត្ថស្រុកដំបែ រារាំងមិនឲ្យចែកសៀវភៅពាក់ព័ន្ធនឹងទិវាសិទ្ធិមនុស្សអន្តរជាតិ និងរបាយការណ៍របស់អង្គការលីកាដូស្តីពីការរំលោភបំពានដីធ្លី។ លោកបានស្នើសុំឯកសារទាំងនោះបន្ទាប់ពីបានចូលរួមសិក្ខាសាលាមួយ របស់សមាគមអាដហុកស្តីពីសិទ្ធិដីធ្លី។

[២៤] ប៊ិច សុធារី "អាជ្ញាធរបញ្ជូនមនុស្ស ២នាក់ក្នុងហិង្សាក្បែរក្រុមហ៊ុនកាពីតូលទៅតុលាការ" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦
[២៥] នៀម ឆេង "តុលាការឃុំខ្លួនអតីតអ្នកបើកបរដែលសង្គមស៊ីវិលថាជាជនរងគ្រោះ" កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦
[២៦] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KS006IAD16
[២៧] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KC010THI16

ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦
ករណីទី២៨

### សកម្មជនការពារបរិស្ថានត្រូវបានផ្តន្ទាទោស[២៨]
### រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- សមាជិកអង្គការមាតាធម្មជាតិចំនួន បីរូប ត្រូវបានចោទប្រកាន់ពីបទសមគំនិតប្រព្រឹត្តបទល្មើស "គំរាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់មកនូវបញ្ហាអ្វីមួយ" ក្នុងនោះមានព្រះសង្ឃ ពីរអង្គ ព្រះតេជគុណ សុខ ចាន់ត្រា ជាលេខាធិការរបស់អង្គការមាតាធម្មជាតិ និងព្រះតេជគុណ ព្រហ្ម ធម្មជាតិ ជានាយកប្រតិបត្តិកិត្តិយសរបស់អង្គការមាតាធម្មជាតិ។ ព្រះសង្ឃទាំងពីរអង្គនោះពុំមានជាប់ពាក់ព័ន្ធនឹងសកម្មភាពប្រចាំថ្ងៃ ឬយុទ្ធនាការអហិង្សាដែល រៀបចំដោយអង្គការមាតាធម្មជាតិ និងមិនមានអំណាចសម្រេចសកម្មភាពការងាររបស់អង្គការមាតាធម្មជាតិឡើយ។ សមាជិកទីបី គឺលោក អាឡិចហ្សង់ដ្រូ ហ្គន់ហ្សាឡេហ្ស ដេវិតសិន សញ្ជាតិអេស្ប៉ាញ ជាស្ថាបនិក និងជានាយកអង្គការមាតាធម្មជាតិ។ ការចោទប្រកាន់ ពីបទសមគំនិតទាំងនេះគឺដូចគ្នាទៅនឹងបទចោទប្រកាន់ទៅលើសកម្មជនរបស់អង្គការមាតាធម្មជាតិបីនាក់ទៀតរួមមានលោក ទ្រី សុវិគា លោក សាន់ ម៉ាឡា និងលោក ស៊ឹម សំណាង។

ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១៦
ករណីទី២៩

### បុគ្គលអង្គការមិនមែនរដ្ឋាភិបាលត្រូវបានរារាំងពីការបណ្តុះបណ្តាលសហគមន៍ជនជាតិដើមភាគតិច[២៩]
### ឃុំកិះចុង ស្រុកបរកែវ ខេត្តរតនគិរី

ការរំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ

- បុគ្គលិកសមាគមអាដហុកប្រចាំខេត្តរតនគិរី ត្រូវបានរារាំងពីការផ្តល់វគ្គបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សដល់សហគមន៍ជនជាតិដើមភាគតិច ដោយកម្លាំងចម្រុះនៃនគរបាល និងកងរាជអាវុធហត្ថស្រុកចំនួន ២០នាក់។ កងកម្លាំងនេះត្រូវបានដឹកនាំដោយអភិបាល ស្តីទីស្រុកបរកែវ មាស សារ៉េត និងមេឃុំកិះចុង រ៉ាជុំ ឡាយ ដែលបានអះអាងថាសមាគម អាដហុកមិនមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន។

ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៦
ករណីទី៣០

### សកម្មជនការពារបរិស្ថានត្រូវបានវាយប្រហារ[៣០]
### តំបន់ព្រៃឡង់ ខេត្តក្រចេះ

ការគំរាមកំហែង – ហិង្សា

- សកម្មជនការពារបរិស្ថាន ផន សុភ័ក្រ្ត មកពីបណ្តាញសហគមន៍ព្រៃឡង់ត្រូវបានជនមិនស្គាល់អត្តសញ្ញាណកាប់នឹងពូថៅ ខណៈដែលកំពុងល្បាតព្រៃឡង់ក្នុងខេត្តក្រចេះ នាំរំលងអធ្រាត្រឈានចូលព្រឹកថ្ងៃអាទិត្យ។ ក្រុមសកម្មជនរបស់បណ្តាញនេះបានស្ទាត់ចាប់បានសកម្មភាពកាប់ឈើជាច្រើនលើកខណៈពេលដើរល្បាតព្រៃ។ សមាជិកបណ្តាញព្រៃឡង់លោក ផៃ ប៊ុនលាង ជឿជាក់ថាការវាយប្រហារនេះ គឺជាការសងសឹករបស់អ្នកកាប់ឈើដែលត្រូវបានក្រុមសកម្មជនចាប់បង្ខំឲ្យចុះហត្ថលេខាលើកិច្ចសន្យាឈប់ប្រព្រឹត្តបទល្មើសទៀត។

ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦
ករណីទី៣១

### មន្ត្រីសហជីពពីររូបត្រូវបានវាយដំ[៣១]
### រាជធានីភ្នំពេញ

ការរំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- មន្ត្រីសហជីពពីររូប បានរងរបួសនៅពេលដែលការប្រមូលផ្តុំដោយសន្តិវិធីនៅក្បែររដ្ឋសភាជាតិ ដើម្បីតវ៉ាជំទាស់នឹងសេចក្តីព្រាងច្បាប់ស្តីពីសហជីព ដែលនឹងត្រូវអនុម័តនៅថ្ងៃនោះ ត្រូវបានបំបែកដោយហិង្សាពីសំណាក់អាជ្ញាធរ។ កម្លាំងនគរបាលដែលឈរនៅក្បែរនោះ មិនបានធ្វើអន្តរាគមន៍បញ្ឈប់អំពើហិង្សារបស់ក្រុមសន្តិសុខ ដែលមានប្រដាប់ដោយដំបងមកលើមន្ត្រីសហ-ជីពឡើយ ។

[២៨] *សេចក្តីថ្លែងការណ៍រួម "អង្គការសង្គមស៊ីវិលសូមប្រកាសគាំទ្រអង្គការមាតាធម្មជាតិ និងថ្កោលទោសចំពោះការបង្ក្រាបទៅលើអង្គការនេះ",* http://www.licadho-cambodia.org/pressrelease.php?perm=399.

[២៩] *របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូនៃលមិនត្រូវបានចេញផ្សាយ៖ RK010OFEA16*

[៣០] *កាសែតភ្នំពេញប៉ុស្តិ៍ "អ្នកការពារព្រៃឡង់ត្រូវអ្នកកាប់ឈើលបកាប់" ដាក់ ស៊ាងលី និងអ៊ិហ៊្វរ កូសសូវ ថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១៦*

[៣១] *កាសែតខេមបូឌា ដេលី "ផ្ទុះអំពើហិង្សានៅក្រៅរដ្ឋសភាខណៈតំណាងរាស្ត្រកំពុងអនុម័តច្បាប់សហជីពនិចម្រូងចម្រាស" គុច ណារ៉េន និងឃួន ណារិម ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦*

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦
ករណីទី៣២

អ្នកវិភាគនយោបាយត្រូវបានប្ដឹងពីបទបរិហារកេរ្តិ៍ពាក់ព័ន្ធនឹង មតិដែលបានបញ្ចេញ[32]
រាជធានីភ្នំពេញ

ការគំរាមកំហែង – ផ្លូវច្បាប់

- អ្នកនាំពាក្យគណបក្សប្រជាជន សុខ ឥសាន បានដាក់ពាក្យបណ្ដឹងពីបទបរិហារកេរ្តិ៍ ជាសាធារណៈទៅលើ អ្នកវិភាគនយោបាយ លោក អ៊ូ វីរៈ។ បណ្ដឹងនេះបណ្ដាលមកពីបទសម្ភាសន៍មួយរបស់លោក អ៊ូ វីរៈ ទៅកាន់វិទ្យុអាស៊ីសេរី ដែលលោកបានអះអាងថារឿងអាស្រូវជុំវិញករណីរបស់ប្រធានស្ដីទីនៃគណបក្សសង្គ្រោះជាតិ គឺមានពាក់ព័ន្ធនឹងគណបក្សប្រជាជន។ លោក អ៊ូ វីរៈ ត្រូវបាន តុលាការរាជធានីភ្នំពេញកោះហៅដើម្បីសួរនាំនៅថ្ងៃទី១២ ខែឧសភា។

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦
ករណីទី៣៣

សូមមើលករណីទី
៣៣ ៣៥ ៣៦ ៤០)

បុគ្គលិកបួននាក់របស់សមាគមអាដហុក និងមន្ត្រីម្នាក់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានឃាត់ខ្លួនពីបទសូកប៉ាន់[33]
រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- បុគ្គលិកបួននាក់ របស់សមាគមអាដហុក រួមមានលោក ណៃ វង់ដា លោក នី សុខា អ្នកស្រី លឹម មុន្នី លោក យី សុខសាន្ត និងអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជាអតីតបុគ្គលិកសមាគមអាដហុក លោកនី ចរិយា ត្រូវបានកោះហៅ និងឃាត់ខ្លួនដើម្បីសួរនាំអស់រយៈពេលពីរថ្ងៃ នៅអង្គភាពប្រឆាំងអំពើពុករលួយ។ នៅថ្ងៃទី០២ ខែឧសភា អ្នកទាំងប្រាំត្រូវបាន បញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការដោយចៅក្រមស៊ើបសួរ ធាម ចិន្ទពិសិដ្ឋ ដែលបានចោទប្រកាន់បុគ្គលិកទាំងបួននាក់របស់សមាគមអាដហុក ពីបទ សូកប៉ាន់សាក្សី តាមមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌ និងចោទប្រកាន់លោក នី ចរិយា ពីបទ សមគំនិតសូកប៉ាន់សាក្សី តាមមាត្រា២៩ និងមាត្រា៥៤៨ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងសំណុំរឿងរបស់ប្រធានស្ដីទីរបស់គណបក្សសង្គ្រោះជាតិ លោក កឹម សុខា។

អ្នកទាំងនោះ ត្រូវបានតុលាការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នរង់ចាំសវនាការនៅក្នុងខែមិថុនា ឆ្នាំ២០១៧ បន្ទាប់ពីបានជាប់ឃុំឃាំងក្នុងពន្ធនាគាររង់ចាំសវនាការអស់រយៈពេលជាងមួយឆ្នាំ។

ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦
ករណី ទី៣៤
(សូមមើលករណីទី ៣៣
៣៥ ៣៦ ៤០)

ក្រុមអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនដីធ្លីចំនួនប្រាំបីនាក់ ត្រូវបានឃាត់ខ្លួន[៣៤]

សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- ក្រុមអ្នកការពារសិទ្ធិមនុស្សចំនួនប្រាំបីនាក់ រួមមាននាយករងផ្នែកតស៊ូមតិនៃអង្គការលីកាដូ លោក ថាវ គឹមសាន រួមជាមួយទីប្រឹក្សាបរទេសចំនួនពីររូប នាយកប្រតិបត្តិនៃសមាគមធាងត្នោត លោកអ៊ី សារុំ និងសកម្មជនដីធ្លីចំនួនបួននាក់ ត្រូវបានឃាត់ខ្លួនអស់ជាច្រើនម៉ោង បន្ទាប់ពីកម្លាំងនគរបាលប្រមាណ ជា៣០០នាក់ បានរាំងខ្ទប់ក្បួនដង្ហែដោយសន្តិវិធី របស់ក្រុមប្រជាពលរដ្ឋ។

ការបំបែក ដោយប្រើកម្លាំងនេះត្រូវបានដឹកនាំដោយស្នងការនគរបាលរាជធានីភ្នំពេញ លោក ជួន សុវណ្ណ អមដោយព្រះរាជអាជ្ញារងរាជធានីភ្នំពេញ លោក សៀង សុខ នៅពេលក្រុមអ្នកការពារ និងសកម្មជនទាំង នេះបានជួបជុំគ្នា និងព្យាយាម ធ្វើដំណើរទៅកាន់ពន្ធនាគារម១ និងម២ ដើម្បីទាមទារឲ្យមានការដោះលែង អ្នកការពារសិទ្ធិមនុស្សដែលជាប់ឃុំចំនួនប្រាំនាក់។ ការតវ៉ានេះគឺជាព្រឹត្តការណ៍ទីមួយនៃយុទ្ធនាការអហិង្សា ថ្ងៃច័ន្ទ ពណ៌ខ្មៅ។

[៣២] កាសែតភ្នំពេញប៉ុស្ត៍ "CPP ដាក់ពាក្យប្ដឹងលោកអ៊ូ វីរៈ និងគំរាមប្ដឹងអ្នកផ្សេងទៀត" Ananth Baglia និងមាស សុខឆា ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ និង "លោកអ៊ូ វីរៈនឹងចូលទៅបំភ្លឺតាមការកោះហៅរបស់តុលាការ" Ananth Baliga និងវង្ស សុខេង ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦

[៣៣] សេចក្ដីថ្លែងការណ៍រួម "សង្គមស៊ីវិលអំពាវនាវឲ្យអាជ្ញាធរបញ្ឈប់ជាបន្ទាន់នូវការយាយីដល់ អ្នកការពារសិទ្ធិមនុស្ស" ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦, https://www.licadho-cambodia.org/pressrelease.php?perm=402

[៣៤] សេចក្ដីថ្លែងការណ៍រួម "សង្គមស៊ីវិលថ្កោលទោសការកើនឡើងនៃការបំភិតបំភ័យអ្នកការពារ សិទ្ធិមនុស្ស" ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦, http://www.licadho-cambodia.org/pressrelease.php?perm=405

ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦
**ករណីទី៣៥**
(សូមមើលករណីទី ៣៣ ៣៤ ៣៦ ៤០)

### ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានកោះហៅដើម្បីសាកសួរ[៣៥]

សង្កាត់ទឹកថ្លា ខណ្ឌសែន សុខ រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- លោក វ៉ន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានកោះហៅដើម្បីសាកសួរនៅប៉ុស្តិ៍នគរបាលសង្កាត់ទឹកថ្លាដោយមន្ត្រីនាយកដ្ឋានសន្តិសុខ លោក ព្រាប ប៊ុអមដោយស្នងការរងនគរបាលរាជធានីភ្នំពេញ លោក ស៊ឹម វុធី ដែលបានចោទ ប្រកាន់លោក វ៉ន់ ពៅថាមានពាក់ព័ន្ធនឹងការបោះពុម្ពអាវយឺតពណ៌ខ្មៅសម្រាប់យុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅ។

ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦
**ករណីទី៣៦**
(សូមមើលករណីទី ៣៣ ៣៤ ៣៥ ៤០)

### សកម្មជនការពារសិទ្ធិដីធ្លីត្រូវបានឃាត់ខ្លួន[៣៦]

សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- សកម្មជនដីធ្លីចំនួនប្រាំនាក់ ត្រូវបានរារាំងមិនឲ្យប្រមូលផ្តុំដើម្បីធ្វើយុទ្ធនាការអហិង្សាថ្ងៃច័ន្ទពណ៌ខ្មៅ និងត្រូវបានឃាត់ខ្លួននៅអធិការដ្ឋាននគរបាលខណ្ឌទួលគោកដើម្បីសាកសួរដោយអធិការនគរបាលខណ្ឌ លោក ហ៊ីន សុធី ។ សកម្មជនទាំងនោះត្រូវបានដោះលែងវិញប៉ុន្មានម៉ោង ក្រោយមកបន្ទាប់ពីបានចុះហត្ថលេខាលើ "កិច្ចសន្យា" ថានឹងបញ្ឈប់សកម្មភាពយុទ្ធនាការរបស់ពួកគេ។ ការឃាត់ខ្លួននេះនៅតែកើតមានបន្តបន្ទាប់ក្នុងអំឡុងពេលធ្វើយុទ្ធនាការនេះ។ រហូតដល់ចុងឆ្នាំ គេឃើញមានការឃាត់ខ្លួនចំនួន ២៨ ដងដែលបានកើតឡើងនៅថ្ងៃទី០៦ ១៣ និង២០ ខែមិថុនា ថ្ងៃទី១៨ ខែកក្កដា និងថ្ងៃទី០៨ និង១៥ ខែសីហា ឆ្នាំ២០១៦។

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦
**ករណីទី៣៧**

### អ្នកនាំពាក្យក្រសួងយុត្តិធម៌ព្រមានអង្គការមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងគេហទំព័រ[៣៧]

រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- អ្នកនាំពាក្យក្រសួងយុត្តិធម៌បានសរសេរសារនៅលើបណ្តាញសង្គមហ្វេកប៊ុកថា គេហទំព័រអំពីរបាយការណ៍អ្នកទោសនយោបាយរបស់អង្គការលីកាដូ បានបំពានមាត្រានៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងអព្យាក្រឹតភាពផ្នែកនយោបាយ។

ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៦
**ករណីទី៣៨**

### សមាជិកសហជីពការងារចំនួនបីរូបត្រូវបានចាប់និងឃាត់ខ្លួន[៣៨]

ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត

ការគំរាមកំហែង - ផ្លូវច្បាប់

- លេខាធិការសហព័ន្ធសហជីពពលកម្មកម្ពុជា យន់ សំបូរ និងសមាជិកសហព័ន្ធសហជីពពលកម្មកម្ពុជាចំនួន ពីរនាក់ទៀត រួមមាន សូ ស៊ីដែន និង មាស តុក ត្រូវបានចាប់និងឃាត់ ខ្លួនអស់រយៈពេលពីរថ្ងៃដោយមន្ត្រីនគរបាលខេត្តកំពត។ ក្រោមការដឹកនាំរបស់ស្នងការ នគរបាលខេត្តលោក ម៉ៅ ច័ន្ទមធុរិទ្ធ ការចាប់ខ្លួននេះបានកើតឡើងបន្ទាប់មានការតវ៉ាពី កម្មករចំនួនប្រមាណ ៤០០នាក់ ដែលទាមទារមិនឲ្យក្រុមហ៊ុនបញ្ឈប់កម្មករចំនួន ១៥នាក់ ពីការងារ និងទាមទារឲ្យមានលក្ខខណ្ឌការងារល្អជាងមុន។

[៣៥] *កាសែតខេមបូឌា ដេលី "នគរបាលសួរនាំប្រធានសមាគមពាក់ព័ន្ធនឹងការបោះពុម្ពអាវយឺត សម្រាប់យុទ្ធនាការ 'ថ្ងៃច័ន្ទពណ៌ខ្មៅ'" បែន សុខហ៊ាន និងឃី សុវណ្ណារី ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦*

[៣៦] *អត្ថបទខ្លីរបស់អង្គការលីកាដូ ""យុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅ"នៅតែបន្តទោះបីអ្នកតំណាងសហគមន៍មួយចំនួនត្រូវបានឃាត់ខ្លួន" ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦,* [http://www.licadho-cambodia.org/flashnews.php?perm=173](http://www.licadho-cambodia.org/flashnews.php?perm=173)

[៣៧] *កាសែតខេមបូឌា ដេលី "មន្ត្រីក្រសួងយុត្តិធម៌ព្រមានអង្គការលីកាដូធ្ងន់ៗពាក់ព័ន្ធទំព័រ 'អ្នកទោសនយោបាយ'" យួន ណារិម និងហ្វូច វ៉ាយត៍ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦*

[៣៨] *របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KP040OFEA16*

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦
ករណីទី៣៩
(សូមមើលករណីទី ៥២ ៥៦)

### អ្នកវិភាគនយោបាយត្រូវបានសម្លាប់[៣៩]
រាជធានីភ្នំពេញ

ឃាតកម្ម

- អ្នកវិភាគនយោបាយដ៏ល្បីឈ្មោះលោកបណ្ឌិត កែម ឡី ត្រូវបានបាញ់សម្លាប់នៅម៉ាតស្ថានីយ៍ប្រេងឥន្ធនៈ កាល់តិច ដែលពោរពេញដោយមនុស្ស និងស្ថិតនៅកណ្ដាលរាជធានីភ្នំពេញ។ ឃាតកម្មនេះកើតឡើងប៉ុន្មានថ្ងៃក្រោយពី លោក កែម ឡី បាននិយាយនៅក្នុងកម្មវិធីវេទិកាអ្នកស្ដាប់វិទ្យុអាស៊ីសេរីអំពីរបាយការណ៍ថ្មីៗ ដែលបានចេញផ្សាយដោយអង្គការអន្តរជាតិ គ្លូបលវីដណេស ដែលមានទីស្នាក់ការនៅទីក្រុងឡុង។ ទោះបីជាមានការបើកសវនាការជំនុំជម្រះជាសាធារណៈទៅលើខ្មាន់កាំភ្លើង នៅថ្ងៃទី០១ ខែមិនា ឆ្នាំ២០១៧ ក៏ដោយ ការស៊ើបសួរករណីឃាតកម្មនោះនៅពុំទាន់មានតម្លាភាព និងភាពគួរឲ្យជឿជាក់គ្រប់គ្រាន់នៅឡើយ។ សវនាការជំនុំជម្រះមានចេតនាមិនធ្វើការបញ្ជាក់ពីមូលហេតុនៃការសម្លាប់ និងធ្វើការជំនុំជម្រះខ្មាន់កាំភ្លើងដោយមិនពិនិត្យសក្ខីកម្មភាគច្រើនរបស់ខ្មាន់កាំភ្លើងនោះ។ សាលក្រមដែលបានចេញបីសប្ដាហ៍បន្ទាប់ពីសវនាការជំនុំជម្រះរយៈពេលបួនម៉ោងនោះ បានផ្ដន្ទាទោស អឿត អាង ដែលហៅក្រៅថា ជួប សម្លាប់ ពីបទមនុស្សឃាតគិតទុកមុន និងពីបទកាន់កាប់អាវុធខុសច្បាប់។ សាលក្រមនេះបានបង្កជាក្ដីបារម្ភយ៉ាងខ្លាំងអំពីភាពពេញលេញនៃដំណើរការព្រហ្មទណ្ឌលើករណីនេះ។

ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦
ករណីទី៤០
(សូមមើលករណីទី ៣៣ ៣៤ ៣៥ ៣៦)

### តំណាងសហគមន៍បឹងកក់ត្រូវបានចាប់ខ្លួន និងជាប់ឃុំនៅពន្ធនាគារ[៤០]
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- តំណាងសហគមន៍បឹងកក់ អ្នកស្រី ទេព វន្នី និងអ្នកស្រី ប៊ូវ សោភា ត្រូវបានចាប់ខ្លួនអំឡុងពេលយុទ្ធនាការដោយសន្តិវិធី "ថ្ងៃច័ន្ទពណ៌ខ្មៅ" នៅក្នុងសហគមន៍បឹងកក់របស់ពួកគេ។ ក្នុងរយៈពេលមួយសប្ដាហ៍ អ្នកទាំងពីរត្រូវបានផ្ដន្ទាទោសពីបទប្រមាថ តាមមាត្រា ៥០២នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវជាប់ពន្ធនាគាររយៈពេលប្រាំមួយថ្ងៃ បន្ទាប់ពីមានការបើកសវនាការ ដែលបានរំលោភលើសិទ្ធិក្នុងការជំនុំជម្រះដោយស្មើភាពគ្នា។

ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦
ករណីទី៤១

### បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួនបីនាក់ជាប់ទោសពីបទបរិហារកេរ្តិ៍[៤១]
រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- បុគ្គលិករបស់អង្គការសមធម៌កម្ពុជាចំនួន បីរូប រួមមាន លោក អៀង វុទ្ធី លោក ឈាង ភា និងលោក ផែន គឹមសុង ត្រូវបានចោទប្រកាន់និងជាប់ទោសពីបទបរិហារកេរ្តិ៍ជាសាធារណៈទោះបីជាការចោទប្រកាន់ទាំងនោះស្ថិតនៅក្រៅវិសាលភាពនៃច្បាប់ព្រហ្មទណ្ឌនៃកម្ពុជាក៏ដោយ។ ក្នុងអំឡុង ពេលថ្លែងបិទសវនាការ ព្រះរាជអាជ្ញាក៏បានលើកឡើងទៅកាន់ចៅក្រមជំនុំជម្រះផងដែរថាមិនមានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ជាសាធារណៈនោះទេ។

ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៦
ករណីទី៤២
(សូមមើលករណីទី៤០ ៤៣ ៥៣ ៥៤)

### សកម្មជនដីធ្លីប្រាំមួយនាក់ និងអ្នកលក់ប៉េងប៉ោងបួននាក់ត្រូវបានចាប់ខ្លួន[៤២]
សង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- សកម្មជនដីធ្លីចំនួនប្រាំមួយនាក់រួមមានទាំង លោកយាយ ង៉ែត យុន អាយុ ៧៧ឆ្នាំ និងអ្នកលក់ប៉េងប៉ោងចំនួន បួននាក់ ត្រូវបានចាប់ និងនាំខ្លួនទៅកាន់អធិការដ្ឋាននគរបាលខណ្ឌដង្កោ ដោយកម្លាំងសន្តិសុខខណ្ឌដង្កោប្រមាណជា ៥០នាក់។ ការចាប់ខ្លួននេះត្រូវបានដឹកនាំដោយអធិការនគរបាលខណ្ឌដង្កោ លោក ជឹម ស៊ីថា នៅពេលដែលអ្នកតវ៉ាប្រមាណជា ១០០នាក់បានប្រមូលផ្តុំនៅមុខពន្ធនាគារព្រៃស ដើម្បីទាមទារឲ្យមានការដោះលែងតំណាងសហគមន៍បឹងកក់អ្នកស្រី ទេព វន្នី ដែលកំពុងជាប់ឃុំ។សកម្មជនដីធ្លីទាំងប្រាំមួយនាក់ត្រូវបានឃាត់ខ្លួនដល់រំលងអធ្រាត្រទើបដោះលែងមកវិញ។

[៣៩] សេចក្តីថ្លែងការណ៍រួម "សង្គមស៊ីវិលកម្ពុជាថ្កោលទោសការសម្លាប់អ្នកវិភាគឯករាជ្យ លោក បណ្ឌិត កែម ឡី" ថ្ងៃទី១១ខែកក្កដាឆ្នាំ២០១៦ http://www.licadho-cambodia.org/pressrelease.php?perm=406

[៤០] សេចក្តីថ្លែងការណ៍រួម "សង្គមស៊ីវិលអំពាវនាវសូមឲ្យមានការដោះលែងសកម្មជនបឹងកក់ជា បន្ទាន់" ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ http://www.licadho-cambodia.org/pressrelease.php?perm=407

[៤១] សេចក្តីថ្លែងការណ៍រួម "សំណុំរឿងបណ្តឹងលើបុគ្គលិកអង្គការសមធម៌កម្ពុជា" ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦, https://www.licadho-cambodia.org/pressrelease.php?perm=408

[៤២] អត្ថបទខ្លីរបស់អង្គការលីកាដូ "សកម្មជនដីធ្លីនិងអ្នកលក់ប៉េងប៉ោងមួយចំនួនត្រូវបានចាប់ខ្លួនអំឡុងពេលធ្វើការតវ៉ាដោយសន្តិវិធីដើម្បីគាំទ្រសកម្មជនដែលកំពុងជាប់ឃុំ" ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៦ http://www.licadho-cambodia.org/flashnews.php?perm=188

ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦
ករណីទី៤៣
(សូមមើលករណីទី ៤០ ៤២ ៥៣ ៥៤)

សកម្មជនដីធ្លីត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ[៤៣]
រាជធានីភ្នំពេញ
ការគំរាមកំហែង - ផ្លូវច្បាប់

- តំណាងសហគមន៍បឹងកក់ចំនួនបួននាក់រួមមានអ្នកស្រី ទេព វន្នី អ្នកស្រី បូ ឆវី អ្នកស្រី ហេង មុំ និងអ្នកស្រីគង់ ចន្ថា ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយខែពី "បទប្រមាថ" និង "រារាំងមន្ត្រីរាជការសាធារណៈដោយមានស្ថានទម្ងន់ទោស" តាមមាត្រា៥០២និងមាត្រា៥០៤ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធទៅនឹងសំណុំរឿងការតវ៉ាករណីដីធ្លីមួយតាំងពីឆ្នាំ២០១១។ ទោសនេះនឹងត្រូវអនុវត្តនៅពេលបណ្តឹងសារទុក្ខត្រូវបានបញ្ចប់។

ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦
ករណីទី៤៤
(សូមមើលករណីទី ៥១)

អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានជាប់ឃុំឃាំង[៤៤]
រាជធានីភ្នំពេញ
ការគំរាមកំហែង - ផ្លូវច្បាប់

- លោក នី ចរិយាដែលកំពុងជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការទាក់ទងនឹងការចោទប្រកាន់ពីបទសមគំនិតសូកប៉ាន់សាក្សី ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយខែពីបទ 'បរិហារកេរ្តិ៍ជាសាធារណៈ ប្តឹងបរិហារបង្កាច់កេរ្តិ៍ និងផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ យោងតាមមាត្រា ៣០៥ ៣១១ និង៥២២ នៃក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជា។ ការចោទប្រកាន់ទាំងនេះកើតឡើងដោយសារការរិះគន់របស់លោក នី ចរិយា អំពីរបៀបដែលអាជ្ញាធរនិងសាលាដំបូងខេត្តសៀមរាបដោះស្រាយជម្លោះដីធ្លីមួយ កាលពីឆ្នាំ២០១៥។ លោកបានស្នើឲ្យមានការស៊ើបអង្កេតលើភាពមិនប្រក្រតីនៃដំណើរការជំនុំជម្រះ និងបានទាមទារឲ្យមានការដោះលែងជនរងគ្រោះនៃការរំលោភបំពានសិទ្ធិចំនួន ពីរនាក់ ដែលតុលាការបាន ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ។

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦
ករណីទី៤៥

អ្នកការពារសិទ្ធិមនុស្សត្រូវបានវាយដំនៅពេលដើរក្បួនអហិង្សា[៤៥]
រាជធានីភ្នំពេញ
ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- កងសន្តិសុខបានវាយដំយ៉ាងឃោរឃៅទៅលើតំណាងសហគមន៍បឹងកក់លោកច័ន្ទ ពុទ្ធិស័ក្ក និងបុគ្គលិកជាន់ខ្ពស់របស់អង្គការលីកាដូ លោក អំ សំអាត ខណៈដែលលោកព្យាយាមបញ្ឈប់អំពើហិង្សាទាំងនោះដោយសន្តិវិធី។ ប្រធានកម្លាំងសន្តិសុខត្រូវបានគេមើលឃើញថាបានចង្អុលជនរងគ្រោះទាំងពីរមុនពេល ដែលអំពើហិង្សាបានផ្ទុះឡើង។ អំពើហិង្សាដោយគ្មានហេតុផលរបស់កម្លាំងសន្តិសុខនេះ បានកើតឡើងអំឡុងពេលនៃការដើរហែក្បួន ដើម្បីប្រារព្ធទិវាលំនៅដ្ឋានពិភពលោក និងបានបណ្តាលឲ្យអ្នកឃ្លាំមើលសិទ្ធិមនុស្ស និងតំណាងសហគមន៍រងរបួសយ៉ាងធ្ងន់ធ្ងរ ។

ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៦
ករណីទី៤៦
(សូមមើលករណីទី ១៣ ១៧ ២០ ២៨)

ការជួបប្រជុំត្រូវបានរារាំងដោយនគរបាល[៤៦]
ឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង
ការរំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ

- សមាជិកអង្គការមាតាធម្មជាតិ សាន់ ម៉ាឡា និងប្រជាពលរដ្ឋចំនួន ១៨នាក់ទៀត ត្រូវបាន រារាំងពីការរៀបចំការប្រជុំនៅក្នុងផ្ទះឯកជនដើម្បីពិភាក្សាអំពីផលប៉ះពាល់នៃការបូមខ្សាច់។ ការជួបប្រជុំនេះត្រូវបានបញ្ឈប់ដោយមន្ត្រីនគរបាលពីរនាក់ ដែលបានទទួលបញ្ជាពីនាយនគរបាលរដ្ឋបាលកោះកាពិ លោក ខៀវ សំអ៊ាង ដែលបានអះអាងថាជនរងគ្រោះមិនបានសុំការ អនុញ្ញាតរៀបចំការប្រជុំ ។

[៤៣] កាសែតភ្នំពេញប៉ុស្តិ៍ "ស្ត្រីសកម្មជនបឹងកក់៤នាក់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារក្នុងម្នាក់ៗ៦ខែ" Ananth Baglia និងឡាយ សាមាន ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦
[៤៤] សេចក្តីថ្លែងការណ៍រួម "សង្គមស៊ីវិលថ្កោលទោសចំពោះការផ្តន្ទាទោសលើអ្នកការពារសិទ្ធិ មនុស្ស លោក នី ចរិយា" ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦, https://www.licadho-cambodia.org/pressrelease.php?perm=409
[៤៥] សេចក្តីថ្លែងការណ៍រួម "ទិវាលំនៅដ្ឋានពិភពលោកត្រូវបានរំខានដោយការវាយដំយ៉ាងធ្ងន់ធ្ងរលើអ្នកការពារសិទ្ធិមនុស្ស" ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦, https://www.licadho-cambodia.org/pressrelease.php?perm=410
[៤៦] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ KK029OFEA16

**ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៦**
**ករណីទី៤៧**

### អាជ្ញាធររារាំងការអប់រំអំពីការចុះឈ្មោះបោះឆ្នោត[៤៧]
### រាជធានីភ្នំពេញ

ការរំលោភបំពានពីអាជ្ញាធរ - ការចាប់ និងឃាត់ខ្លួន

- យុវជនស្ម័គ្រចិត្តជាង ៦០នាក់ រួមមានមកពី មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center) កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) អង្គការយុវជនខ្មែរ និងការអភិវឌ្ឍសង្គម (KYSD) គណៈកម្មាធិការអព្យាក្រឹត និងមិនលំអៀងសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (NICFEC) គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (CPWP) និងក្រុមយុវជនការពារសង្គម និងបរិស្ថាន(SEPY) បានជួបនឹងបញ្ហាប្រឈមជាច្រើននៅពេលដែលពួកគេព្យាយាមរៀបចំធ្វើសកម្មភាពអប់រំផ្សព្វផ្សាយអំពីការចុះឈ្មោះ បោះឆ្នោត អំឡុងពេលព្រះរាជពិធីបុណ្យអុំទូក។ កងកម្លាំងចម្រុះនៃនគរបាល និងសន្តិសុខដែល រក្សាសណ្តាប់ធ្នាប់សម្រាប់ពិធីបុណ្យអុំទូកនៅក្នុងរាជធានីភ្នំពេញបានរំខាន និងរារាំងយុទ្ធនាការអប់រំផ្សព្វផ្សាយនេះ ទោះបីជាយុវជនស្ម័គ្រចិត្តបានមានលិខិតអនុញ្ញាតពីសាលារាជធានីភ្នំពេញក៏ដោយ។ នៅថ្ងៃទី ១៥ ខែវិច្ឆិកា កងកម្លាំងនគរបាលបានឃាត់ខ្លួនយុវជនស្ម័គ្រចិត្ត ចំនួនប្រាំពីរនាក់អស់រយៈពេលបីម៉ោង ហើយដោះលែងវិញបន្ទាប់ពីយុវជនទាំងនោះយល់ព្រមផ្តិតមេដៃលើកិច្ចសន្យាថានឹងបញ្ឈប់សកម្មភាពអប់រំផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតរបស់ពួកគេទៀត។ ក្រុមអាជ្ញាធរក៏បានដកហូតទូរស័ព្ទដៃស្មាតហ្វូនរបស់ មេក្រុមយុវជន ពីរនាក់ទុក រហូតទាល់តែអ្នកទាំងពីរនោះយល់ព្រមផ្តិតមេដៃលើកិច្ចសន្យា ថានឹងបញ្ឈប់យុទ្ធនាការអប់រំផ្សព្វផ្សាយរបស់ពួកគេ។

**ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦**
**ករណីទី៤៨**

### សហគមន៍ត្រូវបានរារាំងពីការប្រារព្ធទិវាសិទ្ធិមនុស្ស[៤៨]
### ឃុំត្រពាំងបី ស្រុកឈូក ខេត្តកំពត

ការបំពានលើសេរីភាពក្នុងការជួបជុំ - អហិង្សា

- ការរៀបចំព្រឹត្តិការណ៍ទិវាសិទ្ធិមនុស្សអន្តរជាតិនៅខេត្តកំពតត្រូវបានរារាំង និងបញ្ឈប់ដោយអាជ្ញាធរខេត្ត។ ប្រជាពលរដ្ឋសហគមន៍ប្រមាណជា ៨០នាក់បានព្យាយាមជួបជុំគ្នាដើម្បីរៀបចំវេទិកាសាធារណៈស្តីពីសិទ្ធិមនុស្ស ក្នុងភូមិស្វាយអង្គ ខេត្តកំពត។ ក្រុមអាជ្ញាធរមូលដ្ឋានដែលដឹកនាំដោយមន្ត្រីរដ្ឋបាលស្រុកឈូក បានចេញបញ្ជាឲ្យអ្នកភូមិផ្អាកសកម្មភាព និងរុះរើរោងជួបជុំ បន្ទាប់ពីអភិបាលខេត្តកំពតបានអះអាងថា ប្រជាពលរដ្ឋចាំបាច់ត្រូវសុំការអនុញ្ញាតដើម្បីរៀបចំវេទិកានេះ។

**ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦**
**ករណីទី៤៩**

### សកម្មជនត្រូវបានរារាំងមិនឲ្យចែកចាយខិតប័ណ្ណ[៤៩]
### ឃុំជ័យឧត្តម ស្រុកលំផាត់ ខេត្តរតនគិរី

ការបំពានពីអាជ្ញាធរ - ផ្សេងៗ

- សកម្មជនសិទ្ធិមនុស្ស ត្រូវបានរារាំងមិនឲ្យចែកខិតប័ណ្ណអំពីសិទ្ធិអ្នកបោះឆ្នោតរបស់សមាគមអាដហុក ដោយមេភូមិ កង ខៀវ ដែលអមដោយមេឃុំ និងចៅសង្កាត់។ លោកត្រូវបានគំរាមចាប់ខ្លួន រហូតទាល់តែអ្នកសម្របសម្រួលក្នុងតំបន់របស់សមាគមអាដហុកបានប្រាប់ មេឃុំថាខិតប័ណ្ណនោះមិនមែនជាខិតប័ណ្ណប្រឆាំងនោះឡើយ។ លោក ត្រូវបាន អាជ្ញាធរប្រាប់ថាលោកត្រូវតែជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានជាមុនសិន នៅពេលដែលលោកចង់ចែកខិតប័ណ្ណអ្វីមួយទាក់ទងនឹងការបោះឆ្នោត។

[៤៧] សេចក្តីថ្លែងការណ៍របស់អង្គការលីកាដូ "សង្គមស៊ីវិលខកចិត្តចំពោះសកម្មភាពរំខាន រារាំង បង្អាក់ទៅលើយុទ្ធនាការផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតអំឡុងពេលព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ" ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦, https://www.licadho-cambodia.org/pressrelease.php?perm=412

[៤៨] អត្ថបទខ្លីរបស់អង្គការលីកាដូ "ព្រឹត្តិការណ៍ទិវាសិទ្ធិមនុស្សអន្តរជាតិត្រូវបានរារាំងពីសំណាក់អាជ្ញាធរខេត្ត" ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦, http://www.licadho-cambodia.org/flashnews.php?perm=199

[៤៩] របាយការណ៍ស៊ើបសួររបស់អង្គការលីកាដូដែលមិនត្រូវបានចេញផ្សាយ៖ RK004OFEA17

ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦
ករណីទី៥០

### អង្គការមិនមែនរដ្ឋាភិបាលត្រូវបានគំរាមកំហែងពាក់ព័ន្ធនឹងរបាយការណ៍អំពីការបញ្ជាំខ្លួនដោះបំណុល និងពលកម្មកុមារ[៥០]

រាជធានីភ្នំពេញ

ការគំរាមកំហែង – ផ្លូវច្បាប់

- រដ្ឋមន្ត្រីក្រសួងការងារ អ៊ិត សំហេង បានចោទប្រកាន់អង្គការលីកាដូពាក់ព័ន្ធនឹងការចេញផ្សាយរបាយការណ៍ស្តីពីការបញ្ជាំខ្លួនដោះបំណុល និងពលកម្មកុមារក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជារបស់ខ្លួនដោយមិនចែកឲ្យក្រសួងជាមុន និងព្រមានថាក្រសួងនឹងចាត់វិធានការបើសិនជារកឃើញថាការអះអាងក្នុងរបាយការណ៍នេះគឺមិនពិត។ រយៈពេលជិត ពីរខែក្រោយ ក្នុងខែកុម្ភៈ ឆ្នាំ២០១៧ លោករដ្ឋមន្ត្រីបានគំរាមចាត់ចំណាត់ការតាមផ្លូវច្បាប់មកលើ អង្គការលីកាដូពាក់ព័ន្ធនឹងរបាយការណ៍ដដែលនេះ ដោយចោទប្រកាន់ថាអង្គការលីកាដូ បំផ្លើសបញ្ហា និងប្រឌិតសេចក្តីអះអាង។

ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧
ករណីទី៥១
(សូមមើលករណីទី ៤៥)

### អ្នកការពារសិទ្ធិមនុស្សត្រូវបានតុលាការកោះហៅឲ្យចូលបំភ្លឺក្នុងនាមជាជនសង្ស័យ[៥១]

រាជធានីភ្នំពេញ

ការគំរាមកំហែង - ច្បាប់

- អ្នកការពារសិទ្ធិមនុស្ស លោក ច័ន្ទ ពុទ្ធិស័ក្ត និងលោក អំ សំអាត ត្រូវបានសាកសួរដោយព្រះរាជអាជ្ញារងមួយរូបពាក់ព័ន្ធនឹងអំពើហិង្សាដែលបានកើតឡើងកាលពីខែតុលា ឆ្នាំ២០១៦ ខណៈពេលដែលក្រុមសន្តិសុខបានបំបែកក្បួនដង្ហែអហិង្សានៃទិវាសិទ្ធិលំនៅដ្ឋានពិភពលោក។ ប្រធានផ្នែកឃ្លាំមើលនិងការពារសិទ្ធិមនុស្សនៃអង្គការលីកាដូ លោក អំ សំអាត និងតំណាងសហគមន៍បឹងកក់ លោក ច័ន្ទ ពុទ្ធិស័ក្ត ត្រូវបានសាកសួររយៈពេលជាងមួយម៉ោងកន្លះ ខណៈដែលប្រជាពលរដ្ឋជាច្រើនមកពីសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានបានប្រមូលផ្តុំគ្នានៅខាងក្រៅសាលាដំបូងរាជធានីភ្នំពេញ។

ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧
ករណីទី៥២
(សូមមើលករណីទី៣៨ ៥៦)

### អ្នកវិភាគនយោបាយត្រូវបានចោទប្រកាន់[៥២]

សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

ការគំរាមកំហែង - ផ្លូវច្បាប់

- អ្នកវិភាគនយោបាយលោក គឹម សុខ ត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបរិហារកេរ្តិ៍ជាសាធារណៈ និងត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារព្រៃស ពាក់ព័ន្ធនឹងបណ្តឹងដែលទើបតែប្តឹងបានរយៈពេលប្រាំថ្ងៃដោយនាយករដ្ឋមន្ត្រី។ លោកត្រូវបានចោទប្រកាន់និងបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការដោយចៅក្រមស៊ើបសួររាជធានីភ្នំពេញ លោក រស់ ពិសិដ្ឋ បន្ទាប់ពីមានការសាកសួរអស់រយៈពេលជាច្រើនម៉ោងដោយព្រះរាជអាជ្ញារង លោក សៀង សុខ។ សំណុំរឿងនេះគឺជាបណ្តឹងទីមួយក្នុងចំណោមបណ្តឹងចំនួនពីរដែលនាយករដ្ឋមន្ត្រីបានប្តឹងមកលើលោក គឹម សុខ ពាក់ព័ន្ធនឹងការអត្ថាធិប្បាយរបស់លោកអំពីករណីឃាតកម្មលើលោក បណ្ឌិត កែម ឡី ដែលត្រូវបានសម្លាប់នៅក្នុងខែកក្កដា ។ បណ្តឹងទីពីរពាក់ព័ន្ធពីបទបរិហារកេរ្តិ៍ជាសាធារណៈ ដូចគ្នាដែរត្រូវបានប្តឹងមកលើរូបលោក នៅពេលលោក គឹម សុខ បានពន្យល់បកស្រាយតាមវិទ្យុអំពីការអត្ថាធិប្បាយរបស់លោកកាលពីមុន។ ការផ្តន្ទាទោសពីបទញុះញង់តម្រូវឲ្យមានការដាក់ទោសជាប់ពន្ធនាគារចន្លោះពី ប្រាំមួយខែ ទៅពីរឆ្នាំ។ លោកនាយករដ្ឋមន្ត្រីក៏បានទាមទារសំណងពីរូបលោកក្នុងបណ្តឹងទាំងពីរនេះ សរុបចំនួន ៥០២ ៥០០ ដុល្លារអាមេរិចផងដែរ។

[៥០] កាសែតខេមបូឌា ដេលី "រដ្ឋមន្ត្រីក្រសួងការងារព្រមានកាន់តែខ្លាំងចំពោះការអះអាងពីពលកម្មកុមារ" ឃួន ណារិម ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ និង "រដ្ឋមន្ត្រីព្រមានអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធរបាយការណ៍សិប្បកម្មឥដ្ឋ" បែន សុខាន ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦

[៥១] សេចក្តីថ្លែងការណ៍របស់អង្គការលីកាដូ "តុលាការចេញដីកាកោះហៅអ្នកការពារសិទ្ធិមនុស្សពីររូប ក្នុងនាមជាជនសង្ស័យ បន្ទាប់ពីអ្នកទាំងពីរត្រូវបានក្រុមសន្តិសុខវាយដំ" ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧, http://www.licadho-cambodia.org/pressrelease.php?perm=417.

[៥២] អត្ថបទខ្លីរបស់អង្គការលីកាដូ "លោកគឹម សុខ អ្នកវិភាគនយោបាយត្រូវបានចោទប្រកាន់ និងបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ" ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ http://www.licadho-cambodia.org/flashnews.php?perm=208

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧
ករណីទី៥៣
(សូមមើលករណីទី ៤០ ៤២ ៤៣ ៥៤)

**សកម្មជនសហគមន៍ត្រូវបានបំពាន[៥៣]**
**សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ**
ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- ក្រុមសន្តិសុខខណ្ឌ៧មករា បានធ្វើការបំបែកយ៉ាងហិង្សាទៅលើស្ត្រី និងកុមារប្រមាណជា ៣៥នាក់ ដែលមកពីសហគមន៍ដីធ្លីនានាក្នុងរាជធានីភ្នំពេញ ខណៈដែលអ្នកទាំងនោះអង្គុយជួបជុំគ្នាដោយសន្តិវិធីនៅខាងក្រៅតុលាការ ក្នុងអំឡុងពេលនៃសវនាការជំនុំជម្រះក្តីរបស់អ្នកស្រី ទេព វន្នី។ ក្រុមសន្តិសុខបានព្យាយាមរុញច្រានអ្នកគាំទ្រយ៉ាងបង្ខំ ដើម្បីឲ្យអ្នកទាំងនោះចាកចេញពីមុខតុលាការ ។ នៅពេលដែលអ្នកទាំងនោះមិនព្រមចាកចេញដោយសារសកម្មភាពហិង្សា ក្រុមសន្តិសុខបានប្រើហិង្សាចាប់ទាញអ្នកទាំងនោះឆ្លងកាត់ថ្នល់ ដែលបណ្តាលឲ្យស្ត្រីបីនាក់រងរបួស (ស្ត្រីពីរនាក់មកពីសហគមន៍បឹងកក់ និងស្ត្រីម្នាក់ទៀតមកពីសហគមន៍បុរីកីឡា)។

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧
ករណីទី៥៤
(សូមមើលករណីទី ៤០ ៤២ ៤៣ ៥៣)

**តំណាងសហគមន៍ត្រូវបានផ្តន្ទាទោសម្តងទៀត[៥៤]**
**រាជធានីភ្នំពេញ**
ការគំរាមកំហែង - ផ្លូវច្បាប់

- តុលាការរាជធានីភ្នំពេញបានផ្តន្ទាទោសតំណាងសហគមន៍បឹងកក់អ្នកស្រី ទេព វន្នី ឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំកន្លះ ដែលត្រូវបានគេចាត់ទុកថាជាចំណាត់ការមានជាប់ពាក់ព័ន្ធរឿងនយោបាយ ពីបទ"ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស" ពាក់ព័ន្ធនឹងការតវ៉ាកាលពីឆ្នាំ ២០១៣ ដែលអ្នកស្រីត្រូវបានចោទប្រកាន់ថាប្រើប្រាស់ហិង្សាទៅលើសន្តិសុខ។

ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧
ករណីទី៥៥

**គណនីប្រព័ន្ធអេឡិចត្រូនិចរបស់សកម្មជនត្រូវបានលួច[៥៥]**
**រាជធានីភ្នំពេញ**
ការគំរាមកំហែង - ផ្សេងៗ

- គណនីបណ្តាញសង្គម និងអ៊ីម៉េលរបស់អ្នកការពារសិទ្ធិមនុស្សជំលេចធ្លោ ត្រូវបានជនអនាមិកលួចយកជាច្រើនលើក ចាប់តាំងពីត្រីមាសដំបូងនៃឆ្នាំ២០១៧។ ជនរងគ្រោះនៃការលួចយកទាំងនោះរួមមានព្រះតេជគុណ លួន សុវ៉ាត លោក ច័ន្ទ ពុទ្ធិស័ក្ក និងអ្នកស្រី ប៊ូវ សោភា។

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧
ករណីទី៥៦
(សូមមើលករណីទី ៣៨ ៥២)

**ក្រុមយុវជនត្រូវបានចាប់ខ្លួនពាក់ព័ន្ធការចាក់បញ្ចាំងវីដេអូ[៥៦]**
**សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ**
ការបំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន

- យុវជនចំនួនបួននាក់ត្រូវបានចាប់ និងឃាត់ខ្លួនអស់រយៈពេលបីម៉ោង បន្ទាប់ពីនគរបាល និងសន្តិសុខបានហាមឃាត់ការចាក់បញ្ចាំងវីដេអូឯកសាររបស់កាសែត Al Jazeera ស្តីពីករណីឃាតកម្មលើអ្នកវិភាគនយោបាយលោកបណ្ឌិត កែម ឡី។ ការចាក់បញ្ចាំងវីដេអូឯកសារនេះត្រូវបានគ្រោងធ្វើឡើងនៅការិយាល័យឯកជនមួយរបស់សមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ ដែលជាអង្គការមួយរបស់សកម្មជននិងអ្នកវិភាគវ័យក្មេង។ អ្នកចូលរួមប្រមាណជា ១៥នាក់ រង់ចាំទស្សនាវីដេអូឯកសារនេះ នៅពេលដែលកងកម្លាំងនគរបាល និងសន្តិសុខប្រមាណជា ៥០នាក់ ដែលប្រដាប់ដោយអាវុធឡោមព័ទ្ធការិយាល័យ និងចាប់ខ្លួនយុវជនទាំងបួននាក់នោះ។ យុវជន មួង សូនី សួងនាគព័ន្ធ រ៉េន ចាន់ឡូត និងហេង សំណាង ដែលជាសមាជិករបស់សមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ ត្រូវបានដោះលែងនៅម៉ោងប្រហែលជា ៦ល្ងាច បន្ទាប់ពីអ្នកទាំងនោះបានចុះហត្ថលេខាលើកិច្ចសន្យាថានឹងឈប់ចាក់បញ្ចាំងខ្សែវីដេអូនេះទៀត បើពុំមានការអនុញ្ញាតពីអាជ្ញាធរ។

[៥៣] សេចក្តីថ្លែងការណ៍រួម "អ្នកស្រីទេព វន្នី ត្រូវបានផ្តន្ទាទោសម្តងទៀតខណៈដែលក្រុមសន្តិសុខបានប្រើប្រាស់អំពើហិង្សាទៅលើអ្នកគាំទ្រអ្នកស្រី" ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧, http://www.licadho-cambodia.org/pressrelease.php?perm=418

[៥៤] សោក ឧត្តមនិងហ្សូច វ៉ាយត៍"សកម្មជនសិទ្ធិដីធ្លីត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ២ឆ្នាំកន្លះស្របពេលមានការវាយតំលើអ្នកតវ៉ា" កាសែតខេមបូឌាដេលី ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧

[៥៥] Ben Paviour "ការឃ្លាំមើលរបស់រដ្ឋាភិបាល" កាសែតខេមបូឌាដេលី ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧ https://www.cambodiadaily.com/weekend/surveillance-state-127681/

[៥៦] អត្ថបទខ្លីរបស់អង្គការលីកាដូ "យុវជនត្រូវបានឃាត់ខ្លួនខណៈដែលមានការហាមចាក់បញ្ចាំងវីដេអូឯកសារ" ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧, http://www.licadho-cambodia.org/flashnews.php?perm=211

www.licadho-cambodia.org